ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅស្តីពី
# ធនធានធម្មជាតិ និង ស្ថានភាពសត្វព្រៃក្នុងប្រព័ន្ធ តំបន់ការពារធម្មជាតិ និង របៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប



២០២០

**ក្រសួងបរិស្ថាន**
**អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ**

## នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោក ខាងជើងបឹងទន្លេសាប

# សៀវភៅស្តីពី ធនធានធម្មជាតិ និង ស្ថានភាពសត្វព្រៃក្នុងប្រព័ន្ធ តំបន់ការពារធម្មជាតិ និង របៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប

រៀបរៀងដោយ **លោក សេង គឹមហ័ត់**
ប្រធានការិយាល័យសិក្សាស្រាវជ្រាវ និងគ្រប់គ្រងទិន្នន័យ

បោះពុម្ពដោយ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

រក្សាសិទ្ធិដោយ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

អាសយដ្ឋានៈ ជាន់ទី២ នៃក្រសួងបរិស្ថាន អគារមរកតតេជោ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
ដីឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

២០២០

# មាតិកា

**អារម្ភកថា** ........ i

**សេចក្តីថ្លែងអំណរគុណ** ........ ii

**១. សេចក្តីផ្តើម** ........ 1

**២. ប្រព័ន្ធតំបន់ការពារធម្មជាតិ** ........ 3

**៣. ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ** ........ 3

**៤. ប្រព័ន្ធតំបន់ការពារធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប** ........ 7

៤.១. ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ........ 13

៤.២. ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ........ 16

៤.៣. ដែនជម្រកសត្វព្រៃបឹងពែរ ........ 19

៤.៤. ដែនជម្រកសត្វព្រៃ «ព្រៃឡង់» ........ 20

៤.៥. ដែនជម្រកសត្វព្រៃព្រះរការ ........ 24

៤.៦. ដែនជម្រកសត្វព្រៃឆែប ........ 26

៤.៧. ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» ........ 29

៤.៨. ដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» ........ 31

៤.៩. តំបន់ការពារទេសភាពអង្គរ ........ 33

៤.១០. តំបន់ការពារទេសភាពព្រះវិហារ ........ 35

៤.១១. តំបន់ការពារទេសភាពទន្សាយផ្ទារ ........ 37

៤.១២. តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ........ 39

៤.១៣. តំបន់ការពារទេសភាពអាងត្រពាំងថ្ម ........ 41

៤.១៤. តំបន់ការពារទេសភាព «ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)» ........ 43

៤.១៥. តំបន់ការពារទេសភាព «នោមដូនសំ» ........ 45

៤.១៦. តំបន់ការពារទេសភាព «សំបូរព្រៃគុក» ........ 47

៤.១៧. តំបន់រ៉ាមសារបឹងទន្លេឆ្មារ ........ 49

៤.១៨. តំបន់រ៉ាមសារស្ទឹងសែន ........ 50

៤.១៩. តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ........ 53

៤.២០. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំជញ្ជាំង ........ 56

៤.២១. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះនេត្រព្រះ ........ 58

៤.២២. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះ-ភ្នំវែង ........ 59
៤.២៣. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំយាយសំ ........ 62
៤.២៤. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់ ........ 64
៤.២៥. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំស្វាយ ........ 66
**៥. វាក្យសព្ទ** ( **ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ, ឆ្នាំ២០០៨** ) ........ 68
**៦. តួនាទី និងភារកិច្ចរបស់ ន.ជ.គ.ជ** ........ 69
**៧. ឯកសារយោង** ........ 70
ឧបសម្ព័ន្ធ១៖ ប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្រ្តខាងជើងបឹងទន្លេសាប ........ 72
ឧបសម្ព័ន្ធ២៖ ប្រភេទសត្វព្រៃកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដែលមានវត្តមាននៅក្នុងតំបន់ទេសភាពប៉ែកខាងជើងនៃប្រទេសកម្ពុជា ........ 74

# អារម្ភកថា

តំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី សំដៅចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការអភិវឌ្ឍដោយចីរភាព។ តំបន់ការពារធម្មជាតិជាប្រភពធនធានសម្បូរបែប និងផ្តល់សេវាកម្មធម្មជាតិដល់តម្រូវការចិញ្ចឹមជីវិត ជាពិសេសជនជាតិដើមភាគតិច និងសហគមន៍ជនបទ។ ជាងនេះទៀត តំបន់ព្រៃធម្មជាតិនៃប្រទេសកម្ពុជា មានសក្តានុពលយ៉ាងធំធេងក្នុងការប្រែក្លាយទៅជាតំបន់ទេសចរណ៍ធម្មជាតិ ដែលរួមចំណែកជួយបង្កើនប្រាក់ចំណូលដល់សហគមន៍មូលដ្ឋាន និងលើកស្ទួយសេដ្ឋកិច្ចជាតិ។

ព្រះរាជាណាចក្រកម្ពុជា មានតំបន់ការពារធម្មជាតិចំនួន២៣កន្លែង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលគ្របដណ្តប់លើផ្ទៃដីសរុប ៣,៣លានហិកតា។ រហូតដល់ខែឧសភា ឆ្នាំ២០២០ ព្រះរាជាណាចក្រកម្ពុជា មានតំបន់ការពារធម្មជាតិចំនួន៦៥កន្លែង និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ (របៀងអភិរក្សជីវៈចម្រុះឦសាន ឧត្តរ និងជួរភ្នំក្រវាញ)។ ទាំងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ គ្របដណ្តប់លើផ្ទៃដីជាង ៧,២លានហិកតា ស្មើនឹងជាង៤0% នៃផ្ទៃដីប្រទេស ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ បច្ចុប្បន្ន ប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា កំពុងរងការគំរាមកំហែងដោយសកម្មភាពខុសច្បាប់នានា ដូចជា ការកាប់រុករានទន្ទ្រានយកដីព្រៃរបស់រដ្ឋធ្វើជាកម្មសិទ្ធិ ការមកតាំងទីលំនៅ ការកាប់ឈើដោយខុសច្បាប់ និងការបរបាញ់សត្វព្រៃ ។ល។ ហេតុនេះ ការវិនិយោគបន្ថែមចំពោះការអភិរក្ស និងការអភិវឌ្ឍដោយចីរភាពលើប្រព័ន្ធតំបន់ការពារធម្មជាតិ គឺជាតម្រូវការចាំបាច់ ដើម្បីធានាឱ្យការគ្រប់គ្រងបានល្អប្រសើរ សម្រាប់ជាផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមដល់មនុស្សគ្រប់ជំនាន់។ កិច្ចការពារ និងថែរក្សាតំបន់ការពារធម្មជាតិត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ សម្រាប់ចូលរួមដោះស្រាយបញ្ហាពិភពលោកក្នុងការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការរក្សាបានសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ សៀវភៅនេះគឺជាមូលដ្ឋានមួយផ្តល់នូវព័ត៌មាន និងទិន្នន័យអំពីស្ថានភាពនៃវត្តមានសត្វព្រៃ ទីជម្រក ព័ត៌មានពាក់ព័ន្ធនឹងធនធានធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ និងតំបន់ទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប ដែលមានសារៈប្រយោជន៍សម្រាប់ប្រើប្រាស់ជាជំនួយស្មារតីដល់មន្ត្រីរាជការ សិស្ស និស្សិត និងអ្នកស្រាវជ្រាវនានា។

ក្នុងនាមអគ្គនាយករដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំទទួលបន្ទុកតាមខេត្តគោលដៅ ដែលតែងតែណែនាំ និងផ្តល់ការគាំទ្រលើការងារគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានជាតិអភិវឌ្ឍន៍ដោយចីរភាព អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលបានសហការក្នុងការផ្តល់ព័ត៌មាន ទិន្នន័យ និងរូបភាពផ្សេងៗ ព្រមទាំងលោកប្រធាន លោក លោកស្រីអនុប្រធាន និងសហការីទាំងអស់នៃនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប ដែលបានរៀបចំបោះពុម្ពសៀវភៅដ៏មានសារៈសំខាន់នេះឡើង។

ថ្ងៃពុធ ៤ រោច ខែទុតិយាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២០

**អគ្គនាយក**

**គឹម ណុច**

# សេចក្តីថ្លែងអំណរគុណ

ជាបឋមក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក **សេង គឹមហ៊ត់** ប្រធានការិយាល័យសិក្សាស្រាវជ្រាវនិងគ្រប់គ្រងទិន្នន័យ នៃនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប ដែលបានខិតខំស្រាវជ្រាវ ប្រមូលព័ត៌មាន ទិន្នន័យអំពីធនធានធម្មជាតិរួមមាន រុក្ខជាតិ សត្វព្រៃ ជីវៈចម្រុះ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតទាំងព័ត៌មានបឋម និងមានស្រាប់ពីប្រភពនានាជាច្រើន រួមទាំងតាមគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងសារព័ត៌មានផ្សេងៗ ដើម្បីយកមករៀបចំចងក្រងជាសៀវភៅស្តីពីធនធានធម្មជាតិ និងស្ថានភាពសត្វព្រៃក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប ដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមអរគុណផងដែរដល់សហការីទាំងអស់នៃនាយដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប ចំពោះការចូលរួមផ្តល់ជាគុចូល និងមតិយោបល់សម្រាប់ការកែលម្អខ្លឹមសារនៅក្នុងសៀវភៅនេះ។ រាល់ព័ត៌មាន និងទិន្នន័យអំពីធនធានធម្មជាតិ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍នៃស្ថានភាពទីជម្រក វត្តមានសត្វព្រៃ និងជីវៈចម្រុះក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប។

ក្នុងនាមនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប ខ្ញុំសូមសម្តែងនូវអំណរគុណគោរពជូន ឯកឧត្តម **ជា សំអាង** រដ្ឋលេខាធិការក្រសួងបរិស្ថាន ឯកឧត្តម **មាស សុផល** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ឯកឧត្តម **សុខខេង នរិន្ទ** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងឯកឧត្តម **គឹម ណុង** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលតែងតែចូលរួមផ្តល់មតិកែលម្អ និងការគាំទ្រលើការងាររៀបចំសៀវភៅនេះ។ ជាងនេះទៀត ខ្ញុំសូមថ្លែងអំណរគុណផងដែរដល់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថាន ជាពិសេស នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ នៃអគ្គនាយដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន នាយកដ្ឋានជីវភាពសហគមន៍ និងនាយកដ្ឋានតំបន់បេតិកភណ្ឌ នៃអគ្គសហគមន៍មូលដ្ឋាន លោក លោកស្រីប្រធាន អនុប្រធាន និងមន្ត្រីមន្ទីរបរិស្ថានខេត្ត នាយកនិងមន្ត្រីឧទ្យានុរក្សពាក់ព័ន្ធ លោក Ben Davis ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដែលបានរួមសហការផ្តល់ព័ត៌មាន ទិន្នន័យ រូបភាពសត្វព្រៃ រូបភាពព្រៃឈើ និងរូបភាពប្រាសាទបុរាណនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប។

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ស្ថិតនៅក្នុងតំបន់ជីវៈចម្រុះឥណ្ឌូ-ភូមា (Myers *et al.* 2000; CEPF 2012) ក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់ ដែលមានជីវៈចម្រុះច្រើនបំផុតលើភពផែនដី និងមានប្រភេទទីជម្រកផ្សេងៗគ្នា ដូចជា ព្រៃស្រោងស្ថិតនៅជួរភ្នំក្រវាញ ព្រៃពាក់កណ្តាលស្រោង ព្រៃរបោះដុះនៅតាមតំបន់ខ្ពង់រាប វាលទំនាប ព្រៃលិចទឹក តំបន់វាលស្មៅលិចទឹកតាមរដូវកាល និងជាអចិន្ត្រៃយ៍ក្នុងតំបន់បឹងទន្លេសាប តំបន់ទំនាបលិចទឹកទន្លេមេគង្គ និងព្រៃកោងកាងដុះតាមតំបន់ឆ្នេរសមុទ្រ (Seng Kimhout *et al.*, 2003; CEPF 2012)។ ព្រៃរបោះបានដុះលាតសន្ធឹងយ៉ាងធំធេងកាលពីអតីតកាលនៅតាមតំបន់អាងទន្លេមេគង្គ បច្ចុប្បន្ន ប្រភេទជម្រកបែបនេះ មាននៅតំបន់ប៉ែកខាងជើង និងខាងកើតនៃប្រទេសកម្ពុជា ហើយនិងនៅតាមតំបន់មួយចំនួនក្នុងប្រទេសឡាវ និងប្រទេសវៀតណាម ដែលស្ថិតនៅជាប់ៗនឹងប្រទេសកម្ពុជាតែប៉ុណ្ណោះ (Tordoff *et al.* 2005)។ ព្រៃរបោះនៅក្នុងតំបន់ទាំងនេះ បង្កើតបានទាំងគម្របព្រៃបើកចំហ និងបិទជិតដុះដាលក្នុងតំបន់វាលស្មៅក្នុងព្រៃពាក់កណ្តាលស្រោងដុះជាផ្ទៃកតូចៗ និងមានត្រពាំងជាច្រើនកន្លែង ដែលមានប្រភពទឹកតាមរដូវកាល និងជាអចិន្ត្រៃយ៍ (CEPF, 2012)។

ប្រទេសកម្ពុជា នៅមានតំបន់ព្រៃរបោះច្រើនជាងគេនៅក្នុងតំបន់អាងទន្លេមេគង្គប៉ែកខាងក្រោម (Tordoff *et al.,* 2005)។ តំបន់ព្រៃរបោះទាំងនេះ មានលក្ខណៈសំខាន់ណាស់ក្នុងការផ្តល់ទីជម្រក និងប្រភពចំណីដល់ពពួកថនិកសត្វ សត្វស្លាប និងឧរង្គសត្វ ដែលជាប្រភេទទទួលរងការគំរាមកំហែងនៅលើពិភពលោក ហើយបច្ចុប្បន្ន ប្រភេទមួយចំនួនបានផុតពូជ និងប្រភេទខ្លះទៀតកំពុងឈានទៅរកការផុតពូជនៅក្នុងតំបន់ឥណ្ឌូចិន មានជាអាទិ៍ ទន្សោង រមាំង និងត្រយងយក្ស។

ជាងនេះទៀត បឹងទន្លេសាបគឺជាបឹងមួយធំបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ វាមានរបបជលសាស្ត្រប្លែកគេជាលក្ខណៈឯកគឺថា នៅរដូវប្រាំងមានលំហូរទឹកពីបឹងទន្លេសាបចូលទៅក្នុងទន្លេមេគង្គរហូតដល់ខែមិថុនា និងនៅរដូវវស្សាមានលំហូរទឹកពីទន្លេមេគង្គចូលទៅបឹងទន្លសាបវិញ បានធ្វើឱ្យជាទឹកក្នុងបឹងទន្លសាបកើនឡើង៥ដងនៃទំហំទឹកនៅក្នុងរដូវប្រាំង និងមានជម្រៅជ្រៅ ធ្វើឱ្យជន់លិចតំបន់ព្រៃលិចទឹកព្រៃគុម្ពោត និងលិចតំបន់វាលស្មៅដែលមានទំហំធំល្វឹងល្វើយ មុននឹងទឹកចាប់ផ្តើមហូរចេញម្តងទៀតពីបឹងទន្លេសាបនៅក្នុងខែតុលា មុនពេលចាប់ផ្តើមវដ្តម្តងទៀត។ បឹងទន្លេសាបមានតម្លៃសង្គម វប្បធម៌ និងបរិស្ថានយ៉ាងមហិមាដែលមិនអាចកាត់ថ្លៃបាន ដោយសារវាជាប្រព័ន្ធជលសាស្ត្រអំណោយផលបំផុតសម្រាប់ជម្រកធនធានមច្ឆជាតិនៅក្នុងពិភពលោក ដែលផ្តល់ឱ្យប្រជាជនកម្ពុជាទទួលបាននូវប្រូតេអ៊ីន ៦០ភាគរយ។ បឹងទន្លេសាបក៏មានសារៈសំខាន់ផងដែរសម្រាប់ពពួកសត្វស្លាបទឹក ពស់ទឹក និងកន្ធាយដែលទទួលរងការគំរាមកំហែងនៅលើពិភពលោក។ តំបន់រ៉ាមសារស្ទួលព្រែកទាល់ មានផ្ទៃដីសរុប ២១.៣៤២ ហិកតា ស្ថិតនៅក្នុងបឹងទន្លេសាប និងមានព្រៃលិចទឹកច្រើនជាងគេ ដែលជាទីជម្រកពងកូនធំបំផុតរបស់ហ្វូងសត្វស្លាបទឹកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងទ្រទ្រង់ពពួកសត្វនោល ដែលមានចំនួនជាង១០ម៉ឺនក្បាល ដូចជា ពពួកត្រយង នោលពណ៌ ទុង ក្រសា កុក ស្មោញ និងក្អែកទឹក។ ពពួកសត្វស្លាបទាំងនេះ រួមមានទាំងហ្វូងត្រដក់ធំផងដែរ បានពងកូននៅក្នុងតំបន់នេះ ដែលមានចំនួនច្រើនទីពីរនៅលើពិភពលោក និងជាកន្លែងពងកូនរបស់ទុងប្រផេះ តែមួយគត់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (WCS: Cambodia's Wonderful Protected Areas and Amazing Wildlife)។

# ទិដ្ឋភាពនៃបឹងទន្លេសាប វាលទំនាបលិចទឹកតាមរដូវកាល និងជាអចិន្ត្រៃយ៍ និងតំបន់រ៉ាមសារស្នូលព្រែកទាល់ ដែលជាទីជម្រកពង-កូន និងផ្តល់ប្រភពចំណី ដល់ពពួកសត្វស្លាបទឹកជាច្រើនប្រភេទ
























## ២. ប្រព័ន្ធតំបន់ការពារធម្មជាតិ

ប្រទេសកម្ពុជាបានបង្កើតតំបន់ការពារធម្មជាតិមុនគេនៅអាស៊ីអាគ្នេយ៍ គឺឧទ្យានជាតិអង្គរដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩២៥។ មកដល់ឆ្នាំ១៩៦៩ ដែនជម្រកសត្វព្រៃចំនួន៦កន្លែងបន្ថែមទៀតត្រូវបានបង្កើតឡើង ដែលគ្របដណ្តប់លើផ្ទៃដីសរុប ២,២លានហិកតា ឬ ស្មើនឹង១២% នៃផ្ទៃដីប្រទេស សម្រាប់ការការពារសត្វព្រៃ ជាពិសេស ពពួកថនិកសត្វធំៗ (National Report on Protected Areas and Development, 2003)។ សង្គ្រាមស៊ីវិលដែលមានរយៈពេលយូរអង្វែង បាននាំឱ្យមានការបាត់បង់នៃប្រព័ន្ធតំបន់ការពារធម្មជាតិទាំងនេះ។ បន្ទាប់ពីសង្គ្រាមស៊ីវិលរ៉ាំរ៉ៃនេះបានត្រូវបញ្ចប់ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតតំបន់ការពារធម្មជាតិចំនួន២៣កន្លែង ដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងតំបន់រ៉ាមសារស្ទឹងត្រែងនៅក្នុងឆ្នាំ១៩៩៦ ដែលប្រព័ន្ធតំបន់ការពារធម្មជាតិទាំងនេះមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៣,៣លានហិកតា ស្មើនឹងជាង១៨% នៃផ្ទៃដីប្រទេស។

តាមរយៈកំណែទម្រង់ស៊ីជម្រៅលើវិស័យបរិស្ថាន និងធនធានធម្មជាតិ រាជរដ្ឋាភិបាលបានផ្ទេរតំបន់ព្រៃការពារ និងតំបន់អភិរក្សព្រៃឈើចំនួន១៣កន្លែង និងតំបន់ព្រៃផ្តល់ផលចំនួន៥កន្លែងផ្សេងទៀតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ដែលមានផ្ទៃដីបន្ថែមសរុប ២.៧១០.០៨៧ហិកតា។ គិតត្រឹមខែឧសភា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតតំបន់ការពារធម្មជាតិចំនួន៦៥កន្លែង រួមមានឧទ្យានជាតិចំនួន១២កន្លែង ដែនជម្រកសត្វព្រៃចំនួន១៩កន្លែង តំបន់ការពារទេសភាពចំនួន១៤កន្លែង តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៨កន្លែង តំបន់រ៉ាមសារ៥កន្លែង (តំបន់រ៉ាមសារស្ទឹងត្រែង និងតំបន់រ៉ាមសារ៤កន្លែងផ្សេងទៀតស្ថិតក្នុងតំបន់ការពារធម្មជាតិដទៃ) និងតំបន់បេតិកភណ្ឌធម្មជាតិចំនួន១១កន្លែង ព្រមទាំងបានបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលចែកជាបីរួមមាន របៀងអភិរក្សជីវៈចម្រុះឦសានមានផ្ទៃដី៧៥៧.៦៦១ហិកតា របៀងអភិរក្សជីវៈចម្រុះឧត្តរមានផ្ទៃដី៥០០.៨១០ហិកតា និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញមានផ្ទៃដី១៦៩.៤៦៩ហិកតា ដែលទាំងប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ គ្របដណ្តប់លើផ្ទៃដីសរុបជាង៧,២លានហិកតា ស្មើនឹងជាង៤០% នៃផ្ទៃដីប្រទេស ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន (ផែនទី ១)។ ក្រសួងបរិស្ថាន បានធ្វើការវាយតម្លៃធនធានគម្របព្រៃឈើជាតិឆ្នាំ២០១៦ ដោយលទ្ធផលបង្ហាញថា ផ្ទៃដីគម្របព្រៃឈើសរុបទូទាំងប្រទេសមានប្រមាណ ៨.៧៤២.៤០១ហិកតា ស្មើនឹង៤៨,១៤% ដែលមានអត្រាប្រែប្រួលគិតជាមធ្យមប្រចាំឆ្នាំគឺ ០,៦៧% (យោងតាមសៀវភៅធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦) និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន១៦៨កន្លែង គ្របដណ្តប់លើផ្ទៃដីសរុប ២៨៥.៦០៩ហិកតា មាននៅក្នុងតំបន់ការពារធម្មជាតិចំនួន២៧កន្លែង ដែលស្ថិតនៅក្នុង១៦ខេត្តនៅទូទាំងប្រទេស ក្នុងនោះមាន១១៣កន្លែង ត្រូវបានទទួលស្គាល់ដោយប្រកាសរបស់ក្រសួងបរិស្ថានរួចហើយ (យោងតាមទិន្នន័យគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ របស់នាយកដ្ឋានជីវភាពសហគមន៍នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន)។

## ៣. ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការការពារ និងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ក្រសួងបរិស្ថានបាននិងកំពុងខិតខំធ្វើកិច្ចការលើការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង ការបោះបង្គោលកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ ការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការទប់ស្កាត់បទល្មើស

ធនធានធម្មជាតិ ការដោះស្រាយទំនាស់ដីធ្លី ការសហការចុះបញ្ជីដីធ្លី និងការរៀបចំផែនទីសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដូចជាដីលំនៅឋាន ដីសមូហភាពជនជាតិដើមភាគតិច សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ និងសម្រាប់ការកំណត់បង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត។ ក្រសួងបរិស្ថាន ក៏បាននិងកំពុងយកចិត្តទុកដាក់ផងដែរ លើការពង្រឹងសមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ ព្រមទាំងរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីៗបន្ថែម ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់សហគមន៍ ដើម្បីជំរុញការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរក្សាតម្លៃវប្បធម៌ និងប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិច។ លើសពីនេះទៀត ក្រសួងបានរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសសម្រាប់គាំទ្របន្ថែមលើការងារគ្រប់គ្រងធនធានធម្មជាតិ ការអនុវត្តច្បាប់ និងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានដូចខាងក្រោម៖

- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២
- ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨
- អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- សារាចរណែនាំលេខ ០៥ ស.រ.ណ.ន. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ដោយសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិដោយបានចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ
- ប្រកាសរបស់ក្រសួងបរិស្ថានស្តីពីបែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍ (២០១៧)
- ប្រកាសអន្តរក្រសួងលេខ ០៦៥ ប្រក ប.ស្ល កយ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ រវាងក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ស្តីពីទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសធនធានធម្មជាតិ
- ប្រកាសលេខ ០១០ ប្រក ប.ស្ល ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងបរិស្ថានស្តីពីបែបបទ និងសិទ្ធិសម្រេចពិន័យអន្តរការណ៍
- ប្រកាសអន្តរក្រសួងលេខ ៤១០ ប្រក ប.ស្ល ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃជាមូលដ្ឋាននៃធនធានធម្មជាតិសម្រាប់ធ្វើការជួសជុលស្តារការខូចខាត
- ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (២០១៧-២០៣១)
- ផែនការសកម្មភាព ដើម្បីអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (២០១៨-២០២២)

- យុទ្ធសាស្ត្រជេងបូកជាតិឆ្នាំ២០១៧-២០២៦ ដែលជាឯកសារគោលសំដៅរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស និងពិភពលោកតាមរយៈការធ្វើឱ្យប្រសើរឡើងការងារគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើ
- ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៨-២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព
- កម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ២០១៨-២០២៧
- ផែនការសកម្មភាពឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ២០១៨-២០២៧
- គោលការណ៍ណែនាំស្តីពីការកំណត់បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ
- សៀវភៅធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦
- កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ នៃប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ២០០៦-២០១៦
- គោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ(ឆ្នាំ២០១៧)
- បានរៀបចំសេចក្តីព្រាង «ក្រមបរិស្ថាននិងធនធានធម្មជាតិ» ដោយការធ្វើសមាហរណកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ជាក្របខ័ណ្ឌគតិយុត្តជាតិ។

ក្រសួងក៏បានអនុវត្តផងដែរនូវអនុសញ្ញាអន្តរជាតិមួយចំនួនលើវិស័យបរិស្ថាន និងការអភិរក្សជីវៈចម្រុះ ដែលប្រទេសកម្ពុជាគឺជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីជីវៈចម្រុះក្នុងឆ្នាំ១៩៩៥ (CBD: http://www.cbd.int) អនុសញ្ញារ៉ាមសារក្នុងឆ្នាំ១៩៩៩ (Ramsar: http://www.ramsar.org ) អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើសត្វព្រៃជិតផុតពូជក្នុងឆ្នាំ១៩៩៧ (CITES: https://www.cites.org/eng ) ។ល។

ជាមួយគ្នានេះ ក៏មានបញ្ហាប្រឈមជាច្រើនផងដែរលើកិច្ចគាំពារ និងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ រួមមានដូចខាងក្រោម៖

- តំបន់ការពារធម្មជាតិភាគច្រើន មិនទាន់បានកំណត់ និងបែងចែកតំបន់គ្រប់គ្រង បោះបង្គោលព្រំ និងរៀបចំផែនការគ្រប់គ្រងនៅឡើយ
- ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកិច្ចគាំពារ និងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិនៅមានកម្រិត
- ចំនួនប្រជាជនមានការកើនឡើង និងមានអ្នកចំណូលស្រុកមកតាំងទីលំនៅដ្ឋានដោយខុសច្បាប់ នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ជាពិសេសនៅតាមតំបន់ដែលមានការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ចំនួនមន្ត្រីឧទ្យានុរក្ស មិនទាន់សមាមាត្រទៅនឹងទំហំផ្ទៃដីនៃតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន ដែលបង្កឱកាសឱ្យមានបទល្មើសកើតមាន ហើយមន្ត្រីឧទ្យានុរក្សតែងតែទទួលនូវការគំរាមកំហែងដោយផ្ទាល់ និងដោយប្រយោលពីជនល្មើស។ សមត្ថភាពរបស់មន្ត្រីឧទ្យានុរក្ស នៅមិនទាន់ឆ្លើយតបនឹងការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ដូចជា ការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធ ការប្រើប្រាស់ឧបករណ៍ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GPS) ការប្រើផែនទី ការសរសេររបាយការណ៍ និងការសរសេរកំណត់ហេតុបទល្មើស ។ល។
- នៅមានការខ្វះខាតឧបករណ៍ សម្ភារ និងមធ្យោបាយ ក្នុងការបំពេញការងារ និងការអនុវត្តច្បាប់។




*ផែនទី ១៖ ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ*

## ៤. ប្រព័ន្ធតំបន់ការពារធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប

ប្រព័ន្ធតំបន់ការពារធម្មជាតិស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប គ្របដណ្តប់ដោយតំបន់វាលស្មៅ ព្រៃគុម្ពោត ព្រៃឫស្សី ព្រៃលិចទឹកតាមរដូវកាល និងជាអចិន្ត្រៃយ៍ ព្រៃរបោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង។ តំបន់ទេសភាពភាគខាងជើងនៃប្រទេសកម្ពុជា នៅសេសសល់ព្រៃរបោះច្រើនជាងគេនៅក្នុងតំបន់ឥណ្ឌូចិន ដែលជាតំបន់មួយទ្រទ្រង់ជីវៈចម្រុះច្រើនក្នុងចំណោម២៥តំបន់នៅលើពិភពលោក និងមានទេសភាពស្អាតបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍សម្រាប់ជីវៈចម្រុះ និងជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកសត្វព្រៃជាច្រើនប្រភេទ។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមកនៅក្នុងតំបន់ទេសភាពភាគខាងជើងនេះ មានថនិកសត្វប្រមាណ៨០ប្រភេទ ដែលក្នុងនោះមានថនិកសត្វធំៗជាច្រើនប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ស្ថិតក្នុងស្ថានភាពជិតផុតពូជ និងរងគ្រោះថ្នាក់ ដូចជា ដំរី ទន្សោងខ្ទីង កែះ ខ្លារខិន ខ្លាពពក រមាំង ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច ទោចម្កុដ ស្វាត្រោស ស្វាព្រាម និងមានសត្វស្លាបប្រមាណ៣៣០ប្រភេទ ក្នុងនោះមានសត្វស្លាបច្រើនប្រភេទកំពុងទទួលរងការគំរាមកំហែងលើពិភពលោក ស្ថិតក្នុងស្ថានភាពជិតផុតពូជ និងរងគ្រោះថ្នាក់ ដូចជា ត្រយងយក្ស (ជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា) ត្រយងចង្កំកស អង្កត់ខ្មៅ ក្រៀល ត្រដក់ធំ ត្រដក់តូច ក្ងោក ទាព្រៃស្លាបស និងត្មាតភ្លើង ត្មាតផេះ និងត្មាតត្នោត (ឧបសម្ព័ន្ធ២)។ តំបន់ទេសភាពភាគខាងជើងនៃប្រទេសកម្ពុជា ក៏ជាទីជម្រកពង-កូនយ៉ាងសំខាន់របស់សត្វត្រយងយក្ស ត្រយងចង្កំកស ត្មាតទាំងបីប្រភេទ ត្រដក់ធំ ត្រដក់តូច សត្វក្រៀល និងសត្វស្លាបទឹកធំៗផ្សេងទៀត។

គិតត្រឹមខែឧសភា ឆ្នាំ២០២០ នៅក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប មានតំបន់ការពារធម្មជាតិចំនួន២៥កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុប ១.៦៧៦.២៧៨,៤១ហិកតា រួមមានឧទ្យានជាតិ១កន្លែង ដែនជម្រកសត្វព្រៃ៧កន្លែង តំបន់ការពារទេសភាព៨កន្លែង តំបន់រ៉ាមសារ២កន្លែង និងតំបន់បេតិកភណ្ឌធម្មជាតិ៧កន្លែង ព្រមទាំងរបៀងអភិរក្សជីវៈចម្រុះឧត្តរដែលមានផ្ទៃដីសរុប៥០០.៨១០ហិកតា ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ (ផែនទី ២ និងឧបសម្ព័ន្ធ១)។

ការគំរាមកំហែងលើពពួកសត្វព្រៃ និងទីជម្រករបស់ពួកវានៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ បណ្តាលមកពីកត្តាជាច្រើនដែលស្ទើរតែទាំងអស់ជាសកម្មភាពខុសច្បាប់ ដូចជា ការកាប់ព្រៃឈើ ការចូលឈូសឆាយ កាប់ឆ្ការ ដុតរុករាន ទន្ទ្រាន និងវាតទីកាន់កាប់ដីព្រៃឈើរបស់រដ្ឋធ្វើជាកម្មសិទ្ធិ និងការបរបាញ់ ការបំពុល និងការជួញដូរសត្វព្រៃខុសច្បាប់ សកម្មភាពរំខានរបស់មនុស្ស និងកត្តាគ្រោះមហន្តរាយធម្មជាតិផ្សេងៗ។

ប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ ស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប ពួកគាត់ភាគច្រើនប្រកបមុខរបរធ្វើស្រែចំការ និងមុខរបររួមផ្សំផ្សេងទៀត ដូចជា ការដងជ័រទឹក ការរកទឹកឃ្មុំ ផ្សិត ទំពាំង ឫសឈើ ដំឡូងព្រៃ មើមរុក្ខជាតិផ្សេងទៀត ការនេសាទ និងការចិញ្ចឹមសត្វ ដែលមុខរបរទាំងនេះជាប្រភពប្រាក់ចំណូលយ៉ាងសំខាន់ រួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់។

យោងតាមរបាយការណ៍ឆ្នាំ២០១៩ របស់មន្ទីរបរិស្ថានខេត្តទាំង៧ និងឯកសារពាក់ព័ន្ធផ្សេងទៀត ប្រព័ន្ធតំបន់ការពារធម្មជាតិស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប ដែលមន្ទីរបរិស្ថានខេត្តនីមួយៗបាន និងកំពុងគ្រប់គ្រង មានដូចខាងក្រោម៖

១.មន្ទីរបរិស្ថានខេត្តព្រះវិហារ មានតំបន់ការពារធម្មជាតិចំនួន៩កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៧៧៤.៥៦៨,៤១ហិកតា រួមមានដូចខាងក្រោម៖

-ដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីប្រមាណ ៨០.៩៧៧ហិកតា

-ដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីប្រមាណ ១១៥.៥៨៩ហិកតា

-ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីប្រមាណ ២៤០.២៧២ហិកតា

-ដែនជម្រកសត្វព្រៃព្រះរការ មានផ្ទៃដីសរុប ៩០.៣៦១ហិកតា

-ដែនជម្រកសត្វព្រៃឆែប មានផ្ទៃដីសរុប ១៩០.០២៧ហិកតា

-ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» មានផ្ទៃដីប្រមាណ ២៤.៩៤៩ហិកតា

-តំបន់ការពារទេសភាពព្រះវិហារ មានផ្ទៃដីសរុប ៥.០០០ហិកតា

-តំបន់ការពារទេសភាព «ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)» មានផ្ទៃដីសរុប ២.១២៤ហិកតា

-តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង មានផ្ទៃដីសរុប ២៥.២៦៩,៤១ហិកតា និង

-របៀងអភិរក្សជីវៈចម្រុះ មានផ្ទៃដីសរុបប្រមាណ ១៩១.៣១៣ហិកតា។

២.មន្ទីរបរិស្ថានខេត្តកំពង់ធំ មានតំបន់ការពារធម្មជាតិចំនួន៦កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៤២១.៧៥៤ហិកតា រួមមានដូចខាងក្រោម៖

-ដែនជម្រកសត្វព្រៃព្រៃឡង់ មានផ្ទៃដីប្រមាណ ១២០.០០០ហិកតា

-ដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីប្រមាណ ២៤២.៥០០ហិកតា

-តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប មានផ្ទៃដីប្រមាណ ២៦.៥២៣ហិកតា

-តំបន់ការពារទេសភាព «សំបូរព្រៃគុក» មានផ្ទៃដីសរុប ៤៣៨ហិកតា

-តំបន់រ៉ាមសារស្ទួលបឹងទន្លេឆ្មារ មានផ្ទៃដីប្រមាណ ២៣.០០០ហិកតា

-តំបន់រ៉ាមសារស្ទឹងសែន មានផ្ទៃដីសរុប ៩.២៩៣ហិកតា និង

-របៀងអភិរក្សជីវៈចម្រុះព្រៃអង់តែន មានផ្ទៃដីប្រមាណ៤៨.០០០ហិកតា ស្ថិតក្នុងស្រុកសន្ទុក និងស្រុកសណ្តាន់។

៣.មន្ទីរបរិស្ថានខេត្តសៀមរាប មានតំបន់ការពារធម្មជាតិចំនួន៨កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ២៣៤.០៦៧ហិកតា រួមមានដូចខាងក្រោម៖

-ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» មានផ្ទៃដីសរុប ៣៧.៥០០ហិកតា

-ដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីប្រមាណ ៣៦.៥៩១ហិកតា

-ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីប្រមាណ ៤១.៦០២ហិកតា

-ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» មានផ្ទៃដីប្រមាណ ២០.០០០ហិកតា

-តំបន់ការពារទេសភាពប្រាសាទអង្គរ មានផ្ទៃដីសរុប ១០.៨០០ហិកតា

-តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប មានផ្ទៃដីប្រមាណ ៤.៨៧១ហិកតា

-តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប មានផ្ទៃដីប្រមាណ ៧៧.៧០៣ហិកតា

-តំបន់រ៉ាមសារស្ទួលបឹងទន្លេឆ្មារ មានផ្ទៃដីប្រមាណ ៥.០០០ហិកតា។

៤.មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ មានតំបន់ការពារធម្មជាតិចំនួន៣កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៥៩.៨៤៨ហិកតា រួមមានដូចខាងក្រោម៖

-តំបន់ការពារទេសភាពបន្ទាយឆ្មារ មានផ្ទៃដីប្រមាណ ៤៥.៧៧៥ហិកតា

-តំបន់ការពារទេសភាព «នោមដូនសំ» មានផ្ទៃដីប្រមាណ ១.៤២៣ហិកតា

-តំបន់ការពារទេសភាពអាងត្រពាំងថ្ម មានផ្ទៃដីសរុប១២.៦៥០ហិកតា។

៥.មន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ មានតំបន់ការពារធម្មជាតិចំនួន៣កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ១៩១.៤០៣ហិកតា រួមមានដូចខាងក្រោម៖

-ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីប្រមាណ ១២២.៦៤៣ហិកតា

-ដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» មានផ្ទៃដីសរុប ៣០.២៥៤ហិកតា

-តំបន់ការពារទេសភាពបន្ទាយឆ្មារ មានផ្ទៃដីប្រមាណ ៣៨.៥០៦ហិកតា។

៦. មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង មានតំបន់ការពារធម្មជាតិចំនួន៦កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៤១២.៧៩១ហិកតា។ ដោយឡែក ខេត្តនេះមានមួយផ្នែកនៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ដែលមានផ្ទៃដីប្រមាណ ១២១.៩០៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប។

៧.មន្ទីរបរិស្ថានខេត្តក្រចេះ មានតំបន់ការពារធម្មជាតិចំនួន៥កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ២២៦.៦១៤ហិកតា។ ដោយឡែក ខេត្តនេះមានមួយផ្នែកនៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីប្រមាណ ១០៤.១១៥ហិកតា ស្ថិតក្នុងភូមិសាស្ត្រខាងជើងបឹងទន្លេសាប។

សម្គាល់៖ ផ្ទៃដីតំបន់ការពារធម្មជាតិនីមួយៗដែលស្ថិតក្នុងរដ្ឋបាលខេត្តចាប់ពី២ខេត្តឡើងទៅ ដែលបណ្តាមន្ទីរបរិស្ថានខេត្តបាននិងកំពុងគ្រប់គ្រង គឺអាស្រ័យទៅតាមភូមិសាស្ត្រជាក់ស្តែង មានន័យថា នៅពេលបូកបញ្ចូលគ្នានៃតួលេខផ្ទៃដីតំបន់ការពារធម្មជាតិមួយដែលកំពុងគ្រប់គ្រងដោយមន្ទីរបរិស្ថានខេត្តនីមួយៗ ទំហំផ្ទៃដីតំបន់ការពារធម្មជាតិនោះ មានតួលេខមិនដូចគ្នាទៅនឹងតួលេខនៃផ្ទៃដីសរុបដែលមាននៅក្នុងព្រះរាជក្រឹត្យ និងអនុក្រឹត្យឡើយ។ ហើយផែនទីដែលត្រូវបានប្រើប្រាស់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យ និងអនុក្រឹត្យ ក៏មិនបានបែងចែកទំហំផ្ទៃដីនៃតំបន់ការពារធម្មជាតិនោះទៅតាមភូមិសាស្ត្រខេត្តនីមួយៗផងដែរ។



ការប្រមូលអនុផលព្រៃឈើរបស់ប្រជាពលរដ្ឋក្នុងដែន.ឆែប
© Eleanor Briggs/WCS Cambodia



សកម្មភាពជងជ័រទឹក © Eleanor Briggs/WCS Cambodia

# ពពួកថនិកសត្វ និងសត្វស្លាប ដែលជិតផុតពូជ មានដោយកម្រ និងងាយរងគ្រោះ កំពុងមានវត្តមាន នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ស្ថិតក្នុងតំបន់ទេសភាពខាងជើងនៃប្រទេសកម្ពុជា


ខ្ទីង ថតបានក្នុងឆ្នាំ២០១០ © WCS Cambodia


ដំរី © WCS Cambodia


ទន្សោង © WCS Cambodia


រមាំង © BirdLife Cambodia


ទោចម្កុដ (ញីខាងឆ្វេង-ឈ្មោលខាងស្តាំ) © Jeremy Holden/Wildlife Alliance


ស្វាព្រាម © Eleanor Briggs/WCS Cambodia


ឆ្កែព្រៃ © AI SUZUKI/WCS Cambodia


ខ្លាពពក © AI SUZUKI /WCS Cambodia



ក្ងោក © Ashish John/WCS Cambodia



ត្រយងយក្ស © Allan Michaud



ត្រយងចង្កំកស © Allan Michaud



ត្មាតភ្លើង ត្មាតត្នោត និងត្មាតផេះ © Eleanor Briggs/WCS Cambodia




*ផែនទី ២៖ ផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្ដីពី របៀងអភិរក្សជីវៈចម្រុះឧត្តរ*

## ៤.១. ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ មានផ្ទៃដីសរុប ៣៧.៥០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប។ ឧទ្យានជាតិនេះមានរយៈកម្ពស់រហូតដល់៥០០ម៉ែត្រ ស្ថិតនៅប៉ែកពាយព្យ និងមានចម្ងាយប្រមាណ៥០គីឡូម៉ែត្រពីក្រុងសៀមរាប ដែលសម្បូរទៅដោយសម្បត្តិបេតិកភណ្ឌវប្បធម៌ ធនធានធម្មជាតិ និងផ្ទាំងថ្មធំៗ។ តាមប្រវត្តិសាស្ត្រ ភ្នំគូលែនត្រូវបានគេជឿថា ជាកន្លែងកំណើតនៃអាណាចក្រខ្មែរ ដែលព្រះបាទជ័យវរ្ម័នទី២ បានឡើងគ្រងរាជ្យជាស្តេចនៅតំបន់នេះ ហើយត្រូវបានប្រជាជនកម្ពុជាចាត់ជាទុកជាតំបន់ពិសិដ្ឋ និងស័ក្តិសិទ្ធសម្រាប់ការគោរពបូជា។ ឧទ្យានជាតិនេះមានសហគមន៍តំបន់ការពារធម្មជាតិចំនួន៥កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុប ១.០៧១ហិកតា និងមានចំនួន៥៨៣គ្រួសារ។




### សក្តានុពលធនធានធម្មជាតិ

យោងតាមការសិក្សាស្រាវជ្រាវកន្លងមក ឧទ្យានជាតិនេះគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោងដែលដុះលាយឡំជាមួយនឹងព្រៃរបោះ ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកសត្វព្រៃជាច្រើនប្រភេទ រួមមាន ថនិកសត្វចំនួន៤៤ប្រភេទ មានជាអាទិ៍ ទោចម្កុដ ស្វាព្រាម ស្វាត្រោស កំប្រុកធំ ញើប្រផេះ សំពោចក្រអូប ធ្មាដាវ សត្វស្លាបមានចំនួន១៩៨ប្រភេទ ដូចជា ស្តេចកូលីត កេងកងតូច ឧរង្គសត្វមានចំនួន៦០ប្រភេទ និងថលជលិកសត្វមានចំនួន៦០ប្រភេទ ដែលក្នុងចំណោមសត្វព្រៃទាំងនេះមានចំនួន២៨ប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ស្ថិតក្នុងស្ថានភាពជិតផុតពូជ និង

វងគ្រោះថ្នាក់ (Hayes B. *at al.*, 2013)។ ក្រៅពីពពួកសត្វព្រៃ មានរុក្ខជាតិចំនួន៧៧៥ប្រភេទត្រូវបានកត់ត្រា ហើយក៏ជាតំបន់មួយដែលផ្តល់ប្រភពទឹកយ៉ាងសំខាន់សម្រាប់ប្រើប្រាស់នៅក្នុងក្រុងសៀមរាបផងដែរ។




## សក្តានុពលទេសចរណ៍ធម្មជាតិ

ទោះបីភ្នំគូលែនមានរយៈកម្ពស់ខ្ពស់ ក៏គេអាចឡើងទៅលើខ្នងភ្នំនេះបានយ៉ាងងាយតាមរថយន្ត ឬ ថ្មើរជើង នៅពេលទៅដល់ជើងភ្នំ គេសង្កេតឃើញមានផ្ទាំងថ្មធំៗ និងដើមឈើដុះអមនៅសងខាងផ្លូវដ៏ស្រស់ត្រកាលគួរឱ្យចង់គយគន់ និងបង្កប់នូវអាថ៌កំបាំងដ៏សន្ធឹកសន្ធាប់ពីអតីតកាលនាសម័យអង្គរ ដែលជារមណីយដ្ឋានមួយក្នុងណោមរមណីយដ្ឋានជាច្រើនក្នុងខេត្តសៀមរាប។ រមណីយដ្ឋានភ្នំគូលែនស្ថិតនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិព្រៃធំ ក្នុងភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប ហើយបច្ចុប្បន្ន រមណីយដ្ឋាននេះបានទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនជារៀងរាល់ថ្ងៃ និងមានប្រជាពលរដ្ឋមកពីទីជិតទីឆ្ងាយ តាំងទីលំនៅប្រកបអាជីវកម្ម កសិកម្មយ៉ាងច្រើនកុះករ។ ភ្នំគូលែនមានរមណីយដ្ឋានធម្មជាតិវប្បធម៌ និងប្រវត្តិសាស្ត្រជាច្រើនកន្លែងដូចជា តំបន់ទឹកធ្លាក់ ព្រះអង្គធំ វាលស្តេចគម្លង់ វាលព្រះសព ព្រះក្រាល សំពៅធ្លាយ ស្ទឹងលិង្គមួយពាន់ និងមានប្រាសាទតូចៗធ្វើអំពីឥដ្ឋជាច្រើនទៀត ដូចជា ប្រាសាទអ្នកតា ប្រាសាទថ្មដាប់ ប្រាសាទរោងចិន ប្រាសាទបល្ល័ង្ក តំបន់ស្រះដំរី ។ល។ ដែលជាកេរដំណែលនៃស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី២បានកសាងឡើង។ ការដែលបន្សល់ទុកនូវកេរដំណែលវប្បធម៌ និងប្រវត្តិសាស្ត្រដ៏ច្រើនបែបនេះរួមផ្សំជាមួយនឹងធម្មជាតិដ៏ស្រស់ត្រកាលថែមទៀតនោះធ្វើឱ្យភ្នំគូលែនក្លាយជាតំបន់ទេសចរណ៍ដ៏ប្រណិតរបស់ខេត្តសៀមរាប។ ភ្នំនេះមានដើមគូលែនព្រៃ (*Litchi chinensis*) ដុះជាច្រើន ដោយហេតុនេះហើយ ទើបគេហៅថា «ភ្នំគូលែន»។


www.latinamericanstudies.org/khmer/kule-1jpg
ទីតាំងអាចមើលឃើញសត្វស្វា
Optimal Langur Viewing
Waterfall ទឹកធ្លាក់
តំបន់ព្រៃឈើ និងផ្ទាំងថ្ម
Boulder Forest
ទីតាំងគយគន់ទេសភាព
Viewpoint
ភូមិព្រះអង្គធំ
Preah Ang Thom Village
Pagoda
វត្ត និង ព្រះអង្គធំ
រូងប្រចៀវ
Bat Cave
លិង្គមួយពាន់
Thousand Lingas
ស្ទឹង
River Spot
Cambodia




តំបន់ស្រះដំរី ថតក្នុងខែតុលា ២០១៩ © សេង គឹមហ៊ត់/ន.ដ.គ.ជ


ស្ទឹងលិង្គមួយពាន់ © លឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ


ស្ទឹងលិង្គមួយពាន់ © លឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ

## ៤.២. ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលមានផ្ទៃដីសរុប ៤០២.៥០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប និងខេត្តព្រះវិហារ។ យោងតាមព្រះរាជក្រឹត្យលេខ រកត/០១៩៥/០៧ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥ ខេត្តឧត្តរមានជ័យ ត្រូវបានបង្កើតឡើងសាជាថ្មីដោយផ្ដាច់ចេញពីខេត្តសៀមរាប ក្រោយឆ្នាំ១៩៧០ ដែលរាល់រចនាសម្ព័ន្ធរដ្ឋបាល ត្រូវបានបំផ្លាញដោយសង្គ្រាម និងត្រូវបានលើកទីតាំងមកដាក់ក្នុងខេត្តសៀមរាប។ បច្ចុប្បន្ន ដែនជម្រកសត្វព្រៃនេះគ្របដណ្ដប់ខេត្តចំនួន៣ គឺខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ មានទំហំផ្ទៃដី២៤០.២៧២ហិកតា និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៤កន្លែងដែលមានផ្ទៃដីសរុប២០.២៤៦ហិកតា ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ មានទំហំផ្ទៃដី១២២.៦៤៣ ហិកតា និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន២កន្លែងដែលមានផ្ទៃដីសរុប៥.៥៣១ហិកតា និង ក្នុងភូមិសាស្ត្រខេត្តសៀមរាប មានទំហំផ្ទៃដី៤១.៦០២ហិកតា និងមានសហគមន៍តំបន់ការពារធម្មជាតិ ចំនួន២កន្លែងដែលមានផ្ទៃដីសរុប២.៨៤០ហិកតា។ នៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេពទាំងមូល មានសហគមន៍តំបន់ការពារធម្មជាតិសរុប១៨កន្លែងដែលគ្របដណ្ដប់លើផ្ទៃដីសរុប ២៨.៦១៧ហិកតា និង មានចំនួន៣.៦៣៩គ្រួសារ។



## សក្តានុពលធនធានធម្មជាតិ

មានប្រភេទទីជម្រកផ្សេងៗគ្នាជាលក្ខណៈឯកនៅក្នុងដែនជម្រកសត្វព្រៃនេះ ដូចជាព្រៃរបោះ ព្រៃពាក់កណ្តាលស្រោង ព្រៃស្រោង និងវាលស្មៅលិចទឹកតាមរដូវកាល ដែលបានផ្តល់ទីជម្រកយ៉ាងសំខាន់ដល់ពពួកថនិកសត្វធំៗ រួមមាន ដំរី ខ្ទីង ទន្សោង រមាំង ខ្លាឃ្មុំ ប្រើស ឈ្លូស កែះ ឆ្កែព្រៃ ខ្លាត្រី ទោចម្កុដ និងខ្លាដំបង (ខ្លាដំបងបានបាត់វត្តមានរហូតដល់បច្ចុប្បន្នក្រោយពីថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្តនៅឆ្នាំ២០០០)។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមក មានថនិកសត្វសរុបចំនួន៤០ប្រភេទ ក្នុងនោះមាន២ប្រភេទជាប្រភេទជិតផុតពូជ ១៥ប្រភេទជាប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក និងមាន១៣ប្រភេទជាប្រភេទដែលមានដោយកម្រនៅក្នុងប្រទេសកម្ពុជា និងមានសត្វស្លាបជាង២៨០ប្រភេទ ដែលមាន១៧ប្រភេទជាប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ក្ងោក ត្រដក់ធំ ត្រដក់តូច ក្រៀល អង្កត់ខ្មៅ ត្រយងយក្ស និងត្រយងចង្កំកស ដែលត្រយងទាំងពីរប្រភេទនេះបានពងកូននៅទីជម្រកព្រៃឈើស្ថិតនៅជិតភូមិត្មាតប៉ើយ។ លើសពីនេះទៀង ដែនជម្រកសត្វព្រៃនេះក៏ជាទីជម្រកយ៉ាងសំខាន់សម្រាប់សត្វក្រៀលបង្កាត់ពូជ និងពងកូននៅរដូវវស្សា និងជាទីជម្រកយ៉ាងសំខាន់របស់សត្វពពួលទឹក ដែលជាប្រភេទជិតផុតពូជនៅលើពិភពលោក។ ព្រៃឈើ និងសារព័ន្ធរុក្ខជាតិក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មិនទាន់ត្រូវបានសិក្សាស្រាវជ្រាវនៅឡើយទេ ប៉ុន្តែបើផ្អែកតាមការសិក្សាស្រាវជ្រាវលើប្រភេទទីជម្រកស្រដៀងគ្នា ដែនជម្រកសត្វព្រៃនេះអាចមានពពួករុក្ខជាតិប្រមាណ១.៥០០ប្រភេទ។ ក្រៅពីវត្តមាននៃធនធានរុក្ខជាតិ និងសត្វព្រៃ មានបុរាណស្ថានចំនួន១០៨ទីតាំង និងហ្វូស៊ីលសត្វសមុទ្រ ត្រូវបានស្រាវជ្រាវរកឃើញនៅក្នុង និងក្បែរព្រំប្រទល់នដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ (យោងតាមទិន្នន័យរបស់នាយកដ្ឋានតំបន់បេតិកភណ្ឌនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន)។



សកម្មភាពចុះពិនិត្យលើការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព (២៧-០៩-២០១៨)

## សក្តានុពលទេសចរណ៍ធម្មជាតិ

មានតំបន់ទេសចរណ៍ធម្មជាតិចំនួន២កន្លែងនៅក្នុងដែនជម្រកសត្វព្រៃនេះ ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ គឺតំបន់ទេសចរណ៍ធម្មជាតិត្នោតប៉ើយជឿនក្រសាំង ស្ថិតនៅក្នុងហាសគមន៍តំបន់ការពារធម្មជាតិត្នោតប៉ើយជឿនក្រសាំងដែលមានផ្ទៃដីសរុប ១.៧៦០ហិកតា ស្ថិតក្នុងឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ទទួលស្គាល់ដោយប្រកាសលេខ០៨៨ ប្រ.ក. បស្ថ អកធ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៤ របស់ក្រសួងបរិស្ថាន និងតំបន់ទេសចរណ៍ធម្មជាតិអភិវឌ្ឍន៍ព្រៃវែង ស្ថិតនៅក្នុងហាសគមន៍តំបន់ការពារធម្មជាតិអភិវឌ្ឍន៍ព្រៃវែងដែលមានផ្ទៃដីសរុប ១.០៧១ហិកតា ក្នុងឃុំត្រយ៉ង ស្រុកគូលែន ខេត្តព្រះវិហារ ទទួលស្គាល់ដោយប្រកាសរបស់ក្រសួងបរិស្ថាននៅឆ្នាំ២០១២។ តំបន់ទេសចរណ៍ទាំងពីរនេះបានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាសត្វត្នោត សត្វត្រយង និងសត្វព្រៃសំខាន់ៗផ្សេងទៀត។ ត្នោតប៉ើយបានមកពីភាសាជនជាតិគួយ និយាយថា «ប៉ើយជាក» មានន័យថា «ចុះងូត ឬ លេងទឹក»។


ត្រយងយក្ស នៅត្នោតប៉ើយ © Peter Spillett ( ៧-២-២០២០ )


ត្រយងចង្កំកស © Peter Spillett ( ៥-២-២០២០ )


ប្រសាទភ្នំសណ្តក © សឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ


ទិដ្ឋភាពព្រៃរបោះក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព


ហ្វូស៊ីលសត្វសមុទ្រ © សឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ


ប្រាសាទចិនស្រមួម © សឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ

## ៤.៣. ដែនជម្រកសត្វព្រៃបឹងពែរ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃបឹងពែរ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលមានផ្ទៃដីសរុប ២៤២.៥០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។ បើតាមភូមិសាស្ត្រជាក់ស្តែង ដែនជម្រកសត្វព្រៃនេះគ្របដណ្តប់ខេត្តចំនួន៣ គឺ ខេត្តព្រះវិហារមានផ្ទៃដី១១៥.៥៨៩,៧៤ហិកតា ខេត្តកំពង់ធំមានផ្ទៃដី៩៨.០០២៣ហិកតា និងខេត្តសៀមរាបមានផ្ទៃដី៣៦.៥៩១ហិកតា។ មានសហគមន៍តំបន់ការពារធម្មជាតិចំនួន១១កន្លែង ដែលមានផ្ទៃដីសរុប១៩.៨០៩ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ មានសហគមន៍តំបន់ការពារធម្មជាតិចំនួន១២កន្លែង ដែលមានផ្ទៃដីសរុប៣៤.៧៩២ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន៣កន្លែង ដែលមានផ្ទៃដីសរុប៩.០៧៣ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប។ នៅក្នុងដែនជម្រកសត្វព្រៃបឹងពែរទាំងមូល មានសហគមន៍តំបន់ការពារធម្មជាតិសរុបចំនួន២៦កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីសរុប ៦៣.៦៧៤ហិកតា និងមានចំនួន ៨.០៤០គ្រួសារ ។



### សក្តានុពលធនធានធម្មជាតិ

យោងតាមការសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ២០០២ មានទាកាប៉ាព្រៃចំនួន១៦ក្បាលត្រូវបានកត់ត្រា ដោយពួកវាកំពុងស្វែងរកចំណីនៅក្នុងត្រពាំងល្វាប្រាំ (UTM: ០៥១០៤៧១-១៤៣៨៦៣១)។ ហើយនៅក្នុងពេលសិក្សាស្រាវជ្រាវនោះ មានការសង្កេតឃើញឈើជាច្រើនត្រូវបានកាប់រំលំដោយខុសច្បាប់ និង

ការកាប់រុករានទន្រ្ទានយកដីព្រៃធ្វើចម្ការ កើតមានឡើងជាច្រើនកន្លែងនៅក្នុងដែនជម្រកសត្វព្រៃនេះ។ យោងតាមរបាយការណ៍ផ្ទាល់មាត់ទទួលបាននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ពី លោក **វុន ធឿន** អតីតនាយកដែនជម្រកសត្វព្រៃបឹងពែរ និងលោក **មាស ញឹម** នាយកដែនជម្រកសត្វព្រៃបឹងពែរ បានឱ្យដឹងថា ក្នុងអំឡុងឆ្នាំ២០០៧-២០១១ មានថនិកសត្វធំៗមួយចំនួនត្រូវបានសង្កេតឃើញ ដូចជា ទន្សោង ខ្លាឃ្មុំ ប្រើស ឈ្លូស ហើយសត្វស្លាបមានដូចជា ត្រដក់ធំ (ឃើញនៅឆ្នាំ២០១៧) ត្រយងយក្ស និងត្រយងចង្កំកស (ឃើញនៅឆ្នាំ២០១៨)។ បច្ចុប្បន្ន មិនសូវមានវត្តមានសត្វព្រៃសំខាន់ៗនៅក្នុងដែនជម្រកសត្វព្រៃនេះទេ ដោយសារការបាត់បង់ទីជម្រក និងមានការរំខានច្រើនពីសកម្មភាពមនុស្ស។

## សក្តានុពលទេសចរណ៍ធម្មជាតិ

បច្ចុប្បន្ន មានសហគមន៍ទេសចរណ៍ធម្មជាតិជីឳកបឹងប្រីយ៍ ដែលមានផ្ទៃដីសរុប២.០៦៥ហិកតា ស្ថិតក្នុងឃុំរមណីយ៍ ស្រុករវៀង ខេត្តព្រះវិហារ ហើយត្រូវបានទទួលស្គាល់ដោយប្រកាសលេខ ០៣១ ប្រ.ក.បស្ក អកជ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៣ របស់ក្រសួងបរិស្ថាន។ សម្រាប់វិស័យទេសចរណ៍ធម្មជាតិនៅក្នុងដែនជម្រកសត្វព្រៃនេះ ភ្ញៀវទេសចរអាចរមានឱកាសទស្សនាកម្សាន្តនូវទេសភាពព្រៃឈើ និងសត្វព្រៃ ថ្នាលបណ្តុះកូនឈើ និងការចិញ្ចឹមសត្វជាលក្ខណៈសហគមន៍។


ត្រដក់ធំ © Jonathan Eams/BirdLife Cambodia


ទាកាប៉ាព្រៃ
© WCS Cambodia

## ៤.៤. ដែនជម្រកសត្វព្រៃ «ព្រៃឡង់»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ៤៣១.៦៨៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តព្រះវិហារ។ ដែនជម្រកសត្វព្រៃនេះមានទំហំផ្ទៃដី១២១.៩០៣ហិកតា និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន៥កន្លែង ដែលមានផ្ទៃដីសរុប៥.០៤៨ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង មានទំហំផ្ទៃដី១២០.០០០ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ មានទំហំផ្ទៃដី១០.៥០០ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តក្រចេះ និងមានទំហំផ្ទៃដី៨០.៩៧៧,៣១ហិកតា និងមានសហគមន៍តំបន់ការពារធម្មជាតិចំនួន៧កន្លែង ដែលមានផ្ទៃដីសរុប ៣៤.៦៨៩ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។ នៅក្នុងដែនជម្រកសត្វព្រៃ «ព្រៃឡង់» ទាំងមូល មានសហគមន៍តំបន់ការពារធម្មជាតិសរុបចំនួន១២កន្លែង ដែលគ្របដណ្តប់លើផ្ទៃដី១៩.៧៣៧ហិកតា និងមានចំនួន៤.២២៥គ្រួសារ។ ពាក្យដែលគេនិយាយថា «ព្រៃឡង់» គឺជាភាសាជនជាតិដើមភាគតិចគួយ ដែលមានន័យថា «ព្រៃឈើរបស់យើង»។



## សក្តានុពលធនធានធម្មជាតិ

យោងតាមការសិក្សាស្រាវជ្រាវ តំបន់ព្រៃឡង់មានប្រភេទព្រៃឈើ និងទីជម្រកចំនួន៨ប្រភេទខុសៗគ្នា ដែលភាគច្រើនគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ ក្រៅពីនេះមានតំបន់ព្រៃចម្រុះដោយព្រៃរបោះដុះលាយឡំជាមួយព្រៃស្រល់ និងព្រៃស្លឹកធំចម្រុះ ព្រៃស្រោងជាំទឹក ព្រៃដុះតាមដងទន្លេ និងតំបន់វាលស្មៅ។ មានរុក្ខជាតិចំនួន៥៣០ប្រភេទ ត្រូវបានគេរកឃើញនៅក្នុងតំបន់ព្រៃឡង់ រួមទាំងប្រភេទកេសរកូល ឬ ផ្កាអរគីដេ (*Peristylus goodyeroides*) ផងដែរ ព្រមទាំងមានថនិកសត្វចំនួន៦០ប្រភេទ រួមមានប្រភេទទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ទោចម្គុជ ទន្សោង ខ្ទីង ដំរី មានសត្វស្លាបចំនួន២៦៦ប្រភេទ ក្នុងនោះមានប្រភេទទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា សត្វក្រៀល ត្រដក់ធំ ត្រដក់តូច សត្វកស កេងកងធំ ក្ងោក ទទាទ្រូងលឿង ត្រសេះធំប្រផេះ មានឧរង្គសត្វចំនួន៤៥ប្រភេទ និងមានថលជលិកសត្វចំនួន២២ប្រភេទ (Hayes B. *at al.*, May 2015) ព្រមទាំងមានវត្តមានប្រាសាទបុរាណផងដែរ។




## សក្តានុពលទេសចរណ៍ធម្មជាតិ

យោងតាមឯកសារនៃការសិក្សាស្រាវជ្រាវ ដែនជម្រកសត្វព្រៃនេះនៅមានធនធានធម្មជាតិច្រើនដែលមានសក្តានុពលលើការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិ។ មានសហគមន៍ទេសចរណ៍ធម្មជាតិរស្មីភូមិពីរគិរីបឹងក្រញ៉ាក ដែលមានទំហំផ្ទៃដី៣.៣៣៧ហិកតា ស្ថិតនៅក្នុងឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។ អ្នកទេសចរមកកម្សាន្តនៅទីនោះអាចទស្សនានូវទិដ្ឋភាពព្រៃឈើ សត្វព្រៃ និងទីទួលបុរាណចាស់ ព្រមទាំងមានបឹងធំមួយ និងផែមាត់ទឹក។










Rhinolophus shameli, Prey Lang
Rhinolophus acuminatus, Prey Lang
R. marshalli, Prey Lang
Murina walstoni, Prey Lang




អណ្ដើកកែ-កខ្មៅ *Siebenrockiella crassicolis*



កេសរកុល ដុះលូតលាស់លើថ្មកំបោរក្នុងដែន.ព្រៃឡង់
Peristylus goodyeroides on limestone, Prey Lang



កេងកងធំ
GREAT HORNBILL *BUCEROS BICORNIS*. © ASHISH JOHN/WCS CAMBODIA.



ប្រាសាទត្រពាំងបកប្រើស ©.លឹម វណ្ណច័ន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ

## ៤.៥. ដែនជម្រកសត្វព្រៃព្រះរការ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃព្រះរការ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ៩០.៣៦១ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ដែលជាតំបន់ការពារបង្កើតសម្រាប់ជារបៀងសត្វព្រៃ រវាងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងដែនជម្រកសត្វព្រៃឆែប។ តំបន់ទាំងនេះរួមគ្នាបង្កើតបានជាផ្នែកដ៏សំខាន់នៃអាងស្តុកទឹកនៅខាងលើស្ទឹងសែនដែលជាដៃទន្លេយ៉ាងធំហូរចាក់ទៅបឹងទន្លេសាប ដែលធ្វើឱ្យប្រភពទឹកនេះមានសារៈសំខាន់សម្រាប់ភាពធន់ទ្រាំនឹងអាកាសធាតុ និងសន្តិសុខស្បៀង។ ដែនជម្រកសត្វព្រៃនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។



## សក្តានុពលធនធានធម្មជាតិ

ដែនជម្រកសត្វព្រៃព្រះរការ គ្របដណ្តប់ដោយតំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ ដែលបានផ្តល់ទីជម្រកដល់សត្វព្រៃជាច្រើនប្រភេទ រួមមានថនិកសត្វចំនួន២៨ប្រភេទ ដែលក្នុងនោះមាន១២ប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ស្ថិតក្នុងស្ថានភាពជិតផុតពូជ និងរងគ្រោះថ្នាក់ ដូចជា ដំរី ខ្ទីង ទន្សោង រមាំង ខ្លាឃ្មុំតូច ហើយមានវត្តមានទោចម្កុដច្រើនស្ថិតនៅលំដាប់ទី២នៅលើពិភពលោក។ មានសត្វស្លាបចំនួន១០ប្រភេទ ដែលមានវត្តមាននៅក្នុងដែនជម្រកសត្វព្រៃព្រះរការ ហើយគេគិតថា អាចមានសត្វស្លាបរហូតដល់២៩ប្រភេទដែលជាប្រភេទទទួលរងការគំរាមកំហែងនៅលើពិភពលោក ស្ថិតក្នុងស្ថានភាពជិតផុតពូជ រងគ្រោះថ្នាក់ និងងាយរងគ្រោះ ដូចជា ត្រយងយក្ស ត្រយងចង្កំកស ក្រៀល ត្រដក់តូច ទាព្រៃស្លាបស ក្ងោក ពីព្រោះវាជារបៀងសត្វព្រៃតភ្ជាប់រវាងដែនជម្រកសត្វព្រៃទាំងពីរ ( WCS: Report on Prey Preah Rokar Wildlife Sanctuary, Cambodia 2016 )។












## សក្តានុពលទេសចរណ៍ធម្មជាតិ



ដែនជម្រកសត្វព្រៃព្រះរការ មានសក្តានុពលសម្រាប់វិស័យទេសចរណ៍ធម្មជាតិដោយនៅមានធនធានធម្មជាតិច្រើន និងមានវត្តមានប្រាសាទបុរាណ ដូចជាប្រសាទខ្នារដែលគេបានកសាងឡើងនៅក្នុងសតវត្សរ៍ទី១០-១១ នៃគ្រិស្តសករាជ។

## ៤.៦. ដែនជម្រកសត្វព្រៃឆែប

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃឆែប ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ១៩០.០២៧ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។ ផ្ទៃដីដែនជម្រកសត្វព្រៃនេះស្ទើរតែទាំងអស់ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ គ្របដណ្តប់ស្រុកចំនួន២ គឺស្រុកជាំក្សាន្ត និងស្រុកឆែប និងមានទីតាំងស្ថិតនៅភាគខាងជើងនៃខេត្តព្រះវិហារ ជាប់ខ្សែបន្ទាត់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងរវាងប្រទេសកម្ពុជា និងប្រទេសឡាវ។ ដើមឡើយវាជា «តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិនិងសត្វព្រៃព្រះវិហារ» ដែលបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ មានសហគមន៍តំបន់ការពារធម្មជាតិចំនួន៤កន្លែងដែលគ្របដណ្តប់លើផ្ទៃដីសរុប ៥.៤៣៣ហិកតា និងមានចំនួន៤២២គ្រួសារ។




### សក្តានុពលធនធានធម្មជាតិ

ដែនជម្រកសត្វព្រៃឆែបគ្របដណ្តប់ដោយព្រៃរបោះ ដែលដុះលូតលាស់ជាផ្ទៃកជាប់គ្នាធំបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ តំបន់ព្រៃរបោះដ៏ធំល្វឹងល្វើយនេះបានផ្តល់ទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វ ដែលមានថនិកសត្វធំៗចំនួន៣០ប្រភេទត្រូវបានកត់ត្រា ដូចជា រមាំង ដំរី ខ្ទីង ទន្សោង ខ្លារខិន ជាពិសេស វាជាតំបន់មានអាទិភាពខ្ពស់សម្រាប់ការអភិរក្សសត្វរមាំង ដែលជាប្រភេទជិតផុតពូជទាំងនៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក និងពពួកសត្វស្លាបដែលជិតផុតពូជ និងរងគ្រោះថ្នាក់ រួមមាន

ត្រយងយក្ស ត្រយងចង្កំកស អង្កត់ខ្មៅ ក្រៀល ត្រដក់ធំ ត្រដក់តូច ក្រោក ទាព្រៃស្លាបស និងសត្វត្មាតទាំងបីប្រភេទ រួមមានត្មាតក្បាលក្រហម ត្មាតផេះ និងត្មាតត្នោត ហើយសត្វស្លាបទាំងនេះបានបង្កាត់ពូជ-ពងកូននៅក្នុងដែនជម្រកសត្វព្រៃនេះ ពិសេសជាទីជម្រកយ៉ាងសំខាន់សម្រាប់សត្វក្រៀលបង្កាត់ពូជ និងពងកូននៅក្នុងរដូវវស្សា។ ក្រុមការងាររបស់មន្ទីរបរិស្ថានខេត្តព្រះវិហារ បានប្រទះឃើញវត្តមានរបស់ទន្សោងមួយហ្វូងនៅក្នុងខែឧសភា ឆ្នាំ២០១៨ កំពុងដើរឆ្លងកាត់ផ្លូវនៅចន្លោះស្នាក់ការអូរក្បាលដំរី និងស្នាក់ការអូរកាប៉ុក។ ក្រុមការងារនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប (លោក អៀម បូផារ៉ាស៊ី និង លោក សេង គឹមហ៊ត់) បានចូលរួមអង្កេតសត្វត្មាតនៅទីតាំងអាហារដ្ឋានត្មាតវាលបឹងទាល់ និងបានសង្កេតឃើញសត្វត្មាតសរុប៣៤ក្បាល (ត្មាតផេះចំនួន២២ក្បាល ត្មាតត្នោតចំនួន៩ក្បាល និងត្មាតក្បាលក្រហមចំនួន៣ក្បាល) ដែលចុះមកស៊ីគំរង់គោងាប់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ នៅវេលាម៉ោង៧ព្រឹក។


សត្វក្រៀល និងសំបុកពងកូន © WCS/Cambodia


ទាព្រៃស្លាបស កំពុងហែលរកចំណីក្នុងអូរគគីរ © Ashish John/WCS Cambodia


ហ្វូងសត្វត្មាតស៊ីគំរង់គោងាប់ក្នុងដែនជម្រកសត្វព្រៃឆែប ក្នុងឆ្នាំ២០២០ © អៀម បូផារ៉ាស៊ី


ហ្វូងទន្សោងក្នុងដែនជម្រកសត្វព្រៃឆែប © អ៊ា សុខា

## សក្តានុពលទេសចរណ៍ធម្មជាតិ

បច្ចុប្បន្ន ដែនជម្រកសត្វព្រៃឆែបមានតំបន់ទេសចរណ៍ធម្មជាតិចំនួន២កន្លែង រួមមានតំបន់ទេសចរណ៍ធម្មជាតិបឹងទាល់ គឺជាទីកន្លែងរៀបចំអាហារដ្ឋានត្មាត (Vulture restaurant) ដែលជាកិច្ចការអភិរក្សសត្វត្មាត និងជាការទាក់ទាញភ្ញៀវទេសចរ ឱ្យមកទស្សនានៅតំបន់នេះ ដោយពួកគាត់អាចមើលឃើញសត្វត្មាតទាំង៣ប្រភេទ មកចោមរោមស៊ីគំរង់នៅទីតាំងនោះ និងតំបន់ទេសចរណ៍ធម្មជាតិអូរគគីរ ជាទីតាំងដែលភ្ញៀវទេសចរ អាចមើលឃើញប្រភេទទាព្រៃស្លាបស ដែលជាប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា និងទទួលរងការគំរាមកំហែងនៅលើពិភពលោកស្ថិតក្នុងស្ថានភាពរងគ្រោះថ្នាក់។ តំបន់ទេសចរណ៍ធម្មជាតិទាំងពីរនេះបានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើន មកទស្សនាក្នុងតំបន់នេះជារៀងរាល់ឆ្នាំ ជាពិសេសនៅក្នុងរដូវប្រាំង។




សត្វត្មាតទាំងបីប្រភេទដូចរូបខាងលើ កំពុងថយចុះនូវចំនួនសរុបរបស់វានៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក ដែលនឹងឈានទៅរកការផុតពូជ ដោយសារកត្តាបាត់បង់ទីជម្រក ការខ្វះប្រភពចំណីអាហារ និងការរងគ្រោះដោយសារការប្រើប្រាស់ថ្នាំពុលកសិកម្ម។ ក្នុងការរួមចំណែកលើការអភិរក្សសត្វត្មាត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីជូនដំណឹងលេខ ៧០២០ សជណ.កសក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបញ្ឈប់ការនាំចូល ការចែកចាយ-ផ្គត់ផ្គង់ និងការប្រើប្រាស់បសុឱសថគ្រប់ប្រភេទដែលមានសារធាតុឌីក្លូហ្វេណាក់ (DICLOFENAK) ឬ ប្រភេទថ្នាំលាយផ្សំគ្រប់ប្រភេទដែលមានសារធាតុឌីក្លូហ្វេណាក់ ក្នុងការព្យាបាលសត្វគ្រប់ប្រភេទដែលអាចប៉ះពាល់ដល់ជីវិតរបស់សត្វត្មាតនៅកម្ពុជា។ យោងតាមការសិក្សាស្រាវជ្រាវកន្លងមកបានឱ្យដឹងថា សត្វត្មាតជាសត្វរំញោចខ្លាំងទៅនឹងសារធាតុ DICLOFENAK ហើយការបាត់បង់ជីវិតរបស់វាភាគច្រើន គឺបណ្តាលមកពីការស៊ីសាកសពសត្វដែលប្រើប្រាស់សារធាតុថ្នាំនេះក្នុងការព្យាបាលសត្វ។

## ៤.៧. ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ ដែលមានផ្ទៃដីសរុប ៤២.០៩៧ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកសង្គមថ្មី និងស្រុកគូលែន នៃខេត្តព្រះវិហារ និងស្រុកជីក្រែង នៃខេត្តសៀមរាប។ ដែនជម្រកសត្វព្រៃនេះមានទំហំផ្ទៃដី ២៤.៩៤៩,៣៦ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងមានទំហំផ្ទៃដី២០.០០០ហិកតាស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប។ ដែនជម្រកសត្វព្រៃនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។




| Id | X | Y |
|---|---|---|
| 1 | 444514 | 1499110 |
| 2 | 447408 | 1499070 |
| 3 | 447470 | 1497460 |
| 4 | 450226 | 1496440 |
| 5 | 450224 | 1498670 |
| 6 | 457017 | 1498820 |
| 7 | 457033 | 1499910 |
| 8 | 459907 | 1500610 |
| 9 | 460406 | 1498650 |
| 10 | 461556 | 1500840 |
| 11 | 472062 | 1496450 |
| 12 | 473777 | 1494570 |
| 13 | 472189 | 1489010 |
| 14 | 473903 | 1489230 |
| 15 | 473908 | 1485320 |
| 16 | 473060 | 1485420 |
| 17 | 471895 | 1484790 |
| 18 | 471049 | 1484190 |
| 19 | 469967 | 1483240 |
| 20 | 470686 | 1481860 |
| 21 | 463297 | 1481670 |
| 22 | 459385 | 1483030 |
| 23 | 454852 | 1482160 |
| 24 | 449973 | 1483810 |
| 25 | 450084 | 1487720 |
| 26 | 448473 | 1488750 |
| 27 | 446722 | 1488750 |
| 28 | 445756 | 1489540 |
| 29 | 445705 | 1491980 |
| 30 | 448144 | 1493320 |
| 31 | 448043 | 1494140 |
| 32 | 444515 | 1494110 |

## សក្តានុពលធនធានធម្មជាតិ

យោងតាមរបាយការណ៍នៃការសិក្សាស្រាវជ្រាវរបស់លោក Ben Davis ដែលបានរស់នៅក្នុងតំបន់ភ្នំត្នោតអស់រយៈពេលប្រមាណ២៧ឆ្នាំដោយគិតត្រឹមឆ្នាំ២០១៩ ដែនជម្រកសត្វព្រៃនេះគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វ ដែលគេកត់ត្រាបានចំនួន២៦ប្រភេទ ក្នុងនោះមានប្រភេទសត្វមួយចំនួនកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ទោចម្កុដ ទន្សោង ស្វាព្រាម ឆ្កែព្រៃ ប្រើស (Ben. Mammal list, June 2017) និងមានសត្វស្លាបចំនួន១៤៦ប្រភេទ ដែលប្រភេទមួយចំនួនកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ត្រយងយក្ស ក្ងោក ទទាជើងបៃតង ត្រដក់តូច សត្វកស និងទាព្រៃស្លាបស (Ben. Bird list, June 2017)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

នៅក្នុងដែនជម្រកសត្វព្រៃនេះមានសក្តានុពលផ្នែកទេសចរណ៍ធម្មជាតិ និងវប្បធម៌ ដោយសារមានប្រាសាទបុរាណដែលអ្នកស្រុកហៅថា ប្រាសាទព្រះខ្ពល គឺជាប្រាសាទបុរាណមានវ័យចំណាស់។ បច្ចុប្បន្ន មានការរៀបចំជាតំបន់ទេសចរណ៍ធម្មជាតិជាបណ្តើរៗ និងគ្រប់គ្រងផ្ទាល់ដោយលោក Ben Davis ហើយមានភ្ញៀវទេសចរជាតិ និងអន្តរជាតិទៅទស្សនាកម្សាន្តជាហូរហែ។


ទោចម្កុដ ញី © Ben Davis


កំប្រុកធំ © Ben Davis


ទោចម្កុដ ឈ្មោល © Ben Davis


ទន្សោង ថតបានដោយម៉ាស៊ីនថតស្វ័យប្រវត្ត


ប្រាសាទព្រះខ្ពល © Ben Davis



ប្រាសាទព្រះខ្ពល © លឹម វណ្ណចន្ទ/នាយកដ្ឋានតំបន់បេតិកភណ្ឌ

## ៤.៨. ដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ ដែលមានផ្ទៃដីសរុប ៣០.២៥៤ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកអន្លង់វែង ស្រុកចុងកាល និងស្រុកសំរោង ខេត្តឧត្តរមានជ័យ។ ដើមឡើយ តំបន់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ដែលបានបង្កើតសហគមន៍ព្រៃឈើចំនួន២កន្លែង គឺសហគមន៍រតនៈរុក្ខាដែលមានផ្ទៃដីសរុប១២.៨៧២ហិកតា និងសហគមន៍សង្ឃរុក្ខាវ័នដែលមានផ្ទៃដីសរុប១៨.២៦១ហិកតា រហូតមកដល់បច្ចុប្បន្នសហគមន៍ព្រៃឈើទាំងពីរនេះ មិនទាន់ត្រូវបានបង្កើតជាសហគមន៍តំបន់ការពារធម្មជាតិនៅឡើយ។



## សក្តានុពលធនធានធម្មជាតិ

ដែនជម្រកសត្វព្រៃនេះគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វសំខាន់ៗ ដូចជា ទន្សោង ខ្ទីង រមាំង ស្វាព្រាម ឆ្កែព្រៃ ប្រើសស្បូវ ឈ្លូស ស្វាក្តាម និងមានប្រភេទសត្វស្លាបដែលកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ត្រយងយក្ស អង្កត់ខ្មៅ ត្រដក់ធំ ក្រៀល ក្ងោក ចង្កៀលខ្យង កេងកង ស្មោញ (យោងតាមពុទ្ធដីការបស់ព្រះមេគុណខេត្តឧត្តរមានជ័យ ព្រះតេជគុណ **ប៊ុន សាលួត** ប្រធានសហគមន៍សង្ឃរុក្ខាវ័ន និងការសម្ភាសន៍ជាមួយលោក **ណុប វណ្ណា** មន្ត្រីឧទ្យានុរក្សប្រចាំស្នាក់ការភ្នំរូងដែកនៃដែនជម្រកសត្វព្រៃនេះ)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

ដែនជម្រកសត្វព្រៃនេះ មានសក្តានុពលសម្រាប់អភិវឌ្ឍជាតំបន់ទេសចរណ៍ធម្មជាតិ និងវប្បធម៌ ដោយយោងតាមគេហទំព័រ Facebook «Lina Phourng» របស់លោកប្រធានមន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ បានសរសេររៀបរាប់នូវលទ្ធផលនៃការសិក្សាស្រាវជ្រាវរយៈពេលខ្លីរបស់ក្រុមការងារ ដែលដឹកនាំដោយកង្វាន់តំបន់បេតិកភណ្ឌនៃក្រសួងបរិស្ថាន បានរកឃើញទីតាំងប្រាសាទបែកបាក់ចំនួន៣កន្លែង រូងភ្នំចំនួន៣កន្លែង និងឡស្លដែកសម័យបុរាណ។







រូបថតពីរសន្លឹកនៅខាងលើ ជាសកម្មភាពចុះល្បាតព្រៃរបស់ព្រះសង្ឃដោយមានការចូលរួមពីប្រជាសហគមន៍ និងការអប់រំផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» រួមនឹងការបំបួសដើមឈើដោយព្រះតេជគុណ **ប៊ុន សាលួត**។ រូបថតបីសន្លឹកនៅខាងក្រោម ជាសកម្មភាពចុះសិក្សាស្រាវជ្រាវរយៈពេលខ្លីរបស់ក្រុមការងារនៃក្រសួងបរិស្ថាន ដើម្បីស្វែងរកទីតាំងប្រាសាទបុរាណនានាក្នុងដែនជម្រកសត្វព្រៃនេះ។

## ៤.៩. តំបន់ការពារទេសភាពអង្គរ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

ប្រទេសកម្ពុជាបានបង្កើតតំបន់ការពារធម្មជាតិដំបូងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នោះគឺជាឧទ្យានជាតិអង្គរ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២៥។ ក្រោយមក ឧទ្យានជាតិនេះត្រូវបានបង្កើតជាតំបន់ការពារទេសភាពអង្គរ ដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលមានផ្ទៃដីសរុប ១០.៨០០ហិកតា ស្ថិតក្នុងខេត្តសៀមរាប។ ប្រាសាទអង្គរវត្ត ត្រូវបានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។ តំបន់ការពារទេសភាពអង្គរ គ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។

ប្រាសាទអង្គរវត្ត ត្រូវបានសាងសង់នៅដើមសតវត្សរ៍ទី១២ ដោយព្រះបាទសូរ្យវរ្ម័នទី២ (១១១៣-១១៥០) ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុក្នុងព្រហ្មញ្ញសាសនា។ តាមសិលាចារឹកនៅសតវត្សទី១៦បញ្ជាក់ថា ឈ្មោះប្រាសាទអង្គរវត្ត គឺព្រះមហានគរវេន្រ្ទប្រ័ស្តព្រះពិស្ណុលោក។ ឈ្មោះថា អង្គរវត្ត គឺជាឈ្មោះសាមញ្ញ សម្រាប់កំណត់ប្រាសាទដែលជាបូជនីយដ្ឋាននេះ។ ចំពោះប្រជាជនខ្មែរ ជាពិសេសអ្នករស់នៅខេត្តសៀមរាប ច្រើននិយមហៅឈ្មោះរួមមួយថា អង្គរតូច។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធនៅលើពិភពលោកទាំងអស់បានកំណត់ហៅឈ្មោះរួមមួយថា អង្គរវត្តរហូតមកដល់បច្ចុប្បន្ន (www.mcfa.gov.kh)។ ហើយអាជ្ញាធរជាតិអប្សរាមានភារកិច្ចការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (http://apsaraauthority.gov.kh)។




### សក្តានុពលធនធានធម្មជាតិ

នៅខាងក្នុងតំបន់អង្គរ ព្រៃឈើត្រូវបានការពារយ៉ាងល្អបំផុត និងមានដើមឈើដែលមានវ័យចំណាស់ជាងគេមួយចំនួននៅក្នុងប្រទេស។ ភ្ញៀវទេសចរទាំងឡាយចូលទៅតំបន់អង្គរពីខេត្តសៀមរាប

ដោយធ្វើដំណើរតាមផ្លូវ ដែលគ្របដណ្ដប់ដោយម្លប់ដើមឈើខ្ពស់ៗទាំងអស់នោះ ដូចជាឈើទាលជាប្រភេទដុះច្រើនលប់ដែលមានកម្ពស់រហូតដល់៥០ម៉ែត្រ និងអង្កត់ផ្ចិតទំហំ២ម៉ែត្រ ដើមស្រទ្បៅ និងមានរុក្ខជាតិផ្កាជាច្រើនប្រភេទទៀត ដូចជា កេសរកូល (ផ្កាអ័រគីដេ) ខ្ញីព្រៃ និងរុក្ខជាតិផ្កាស៊ីសត្វល្អិតជាអាហារ (http://angkor.com.kh/environment/flora/)។ មានសត្វស្លាបជិត១០០ប្រភេទ ត្រូវបានរកឃើញ (www.samveasna.org/bird-sites.html) រីឯថនិកសត្វ និងសត្វល្អិតក៏មានច្រើនផងដែរ ប៉ុន្តែមិនទាន់មានការសិក្សាលម្អិតនៅឡើយ។

### សក្ដានុពលទេសចរណ៍ធម្មជាតិ

រមណីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រនេះ ទទួលបានភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាយ៉ាងច្រើនកុះករជារៀងរាល់ថ្ងៃ ដោយយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៧របស់អាជ្ញាធរជាតិអប្សរា មានភ្ញៀវទេសចរអន្តរជាតិទិញប័ណ្ណចូលទស្សនាអង្គរចំនួន២.១៨៩.៨០៤នាក់។












## ៤.១០.តំបន់ការពារទេសភាពព្រះវិហារ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាពព្រះវិហារ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ដែលមានផ្ទៃដីសរុប ៥.០០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។ ប្រាសាទព្រះវិហារ ស្ថិតនៅលើខ្នងភ្នំដងរែកដែលមានរយៈកម្ពស់៦២៥ម៉ែត្រធៀបទៅនឹងទឹកសមុទ្រ មានប្រវែង៨០០ម៉ែត្រ និងទទឹង៤០០ម៉ែត្រ ក្នុងភូមិស្វាយជ្រំ ឃុំកន្ទួត ស្រុកជាំក្សាន្ត មានចម្ងាយ៤០៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ តែបើគេធ្វើដំណើរចេញពីទីរួមខេត្តព្រះវិហារវិញ មានចម្ងាយត្រឹមតែ១០៨គីឡូម៉ែត្រប៉ុណ្ណោះ ដោយធ្វើដំណើរតាមផ្លូវលេខ២១១ ទៅកាន់ស្រុកជាំក្សាន្ត។ ភ្នំដងរែកមានជណ្ដើរមួយដែលគេអាចឡើងទៅដល់កំពូលភ្នំដែលជាទីតាំងរបស់ប្រាសាទព្រះវិហារ ហើយមានលក្ខណៈចោតខ្លាំង។ តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។

អ្នកលក់ដូរ និងប្រជាពលរដ្ឋរស់នៅតំបន់នោះភាគច្រើនតែងតែឡើងទៅលើភ្នំតាមផ្លូវស៊ី១ ពីព្រោះថា ផ្លូវនោះងាយស្រួលក្នុងការធ្វើដំណើរ។ ប្រាសាទព្រះវិហារ គឺជាតំបន់ប្រវត្តិសាស្ត្រមួយដែលមានឈ្មោះថា «សិខរីស្វរៈ» មានន័យថា «អំណាចនៃភ្នំ» ហើយត្រូវបានសាងសង់ឡើងនៅក្នុងអំឡុងចុងសតវត្សទី៩ និងដើមសតវត្សទី១០ ដោយព្រះមហាក្សត្រ៤អង្គ ព្រះនាមព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០) ព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០) ព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០) និងព្រះបាទជ័យវរ្ម័នទី៦ (គ.ស.១០៨០-១១០៩)។ ប្រាសាទព្រះវិហារ ត្រូវបានទាមទារពីប្រទេសថៃមកវិញដោយការកាត់សេចក្ដីពីតុលាការអន្តរជាតិក្រុងឡាអេ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រខ្មែរ។ ហើយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ អង្គការ UNESCO បានសម្រេចដាក់ប្រាសាទព្រះវិហាររបស់កម្ពុជាចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ អាជ្ញាធរជាតិព្រះវិហារមានភារកិច្ចការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ (http://www.preahvihearauthority.gov.kh)។ តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។



### សក្តានុពលធនធានធម្មជាតិ

មិនទាន់រកឃើញរបាយការណ៍ ឬ ឯកសារណាមួយពិពណ៌នាអំពីធនធានធម្មជាតិ និងសត្វព្រៃនៅក្នុងតំបន់ការពារទេសភាពនេះនៅឡើយទេ។

### សក្តានុពលទេសចរណ៍ធម្មជាតិ

ប្រាសាទព្រះវិហារ គឺជារមណីយដ្ឋានវប្បធម៌ធម្មជាតិ ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទស្សនាយ៉ាងច្រើនជារៀងរាល់ថ្ងៃ ដែលមានចំនួនប្រមាណ១០០.២៩៣នាក់ក្នុងរយៈពេល១០ខែក្នុងឆ្នាំ២០១៧ (http://freshnewsasia.com/index.php/en/localnews/69338-2017-11-03-05-18-21.html)។







## ៤.១១.តំបន់ការពារទេសភាពទន្លាយធ្មារ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាពទន្លាយធ្មារ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលមានផ្ទៃដីសរុប ៨១.២០០ហិកតា ស្ថិតក្នុងខេត្តបន្ទាយមានជ័យ។ បើតាមភូមិសាស្ត្រជាក់ស្តែង តំបន់ការពារទេសភាពនេះគ្របដណ្តប់ខេត្តចំនួន២គឺ ខេត្តបន្ទាយមានជ័យ មានផ្ទៃដីសរុបប្រមាណ ៤៥.៧៧៥ហិកតា ស្ថិតក្នុងស្រុកថ្មពួក និងខេត្តឧត្តរមានជ័យ មានផ្ទៃដីសរុបប្រមាណ ៣៨.៥០៦ហិកតា ស្ថិតក្នុងស្រុកបន្ទាយអំពិល។ មានសហគមន៍តំបន់ការពារធម្មជាតិចំនួន២កន្លែង ដែលផ្ទៃដីសរុប ៩០០ ហិកតា និងមានចំនួន១៩៤គ្រួសារ ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។

ប្រាសាទបន្ទាយធ្មារ មានតម្លៃជាប្រវត្តិសាស្ត្របង្កប់នូវភាពអាថ៌កំបាំង មានរូបថ្មចារឹកដៃ៣២ មានអមដោយប្រាសាទរណបជុំវិញ ដែលបានកសាងឡើងនៅចុងសតវត្សទី១២ ដើមសតវត្សទី១៣ ដោយព្រះមហាក្សត្រព្រះបាទជ័យវរ្ម័នទី៧ ក្នុងគោលបំណងដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធព្រះរាជបុត្រារបស់ព្រះអង្គព្រះនាមសិន្ទ្រៈកុមារ និងឧទ្ទិសវិញ្ញាណក្ខន្ធមេទ័ពទាំង៤ដែលបានពលីជីវិតក្នុងសមរភូមិសង្គ្រាម នៅគ្រាប្រយុទ្ធជាមួយមេទ័ពចំប៉ា។ ប្រាសាទបន្ទាយធ្មារ បានទទួលរងការខូចខាតជាខ្លាំងដោយកត្តាមនុស្ស និងធម្មជាតិ នៅក្នុងពេលដែលប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាមស៊ីវិល មានក្រុមមនុស្សទុច្ចរិតមួយចំនួនបានបំផ្លិចបំផ្លាញដោយជីគាស់កកាយយកវត្ថុបុរាណក្នុងប្រាសាទ ទៅជួញដូរក្រៅប្រទេសដោយខុសច្បាប់ បណ្តាលឱ្យថ្មបាក់ដួលរលំរាយប៉ាយ ម្យ៉ាងទៀតប្រាសាទរងការខូចខាតដោយគ្រោះធម្មជាតិ ខ្យល់ព្យុះបក់បោកដួលដើមឈើរលំពីលើប្រាសាទជាដើម។ ប្រាសាទបន្ទាយធ្មារ ត្រូវបាននិងកំពុងជួសជុលកែលម្អឡើងវិញជាបណ្តើរៗនៅតាមផ្នែកមួយចំនួនក្នុងប្រសាទ និងត្រូវបានការពារ អភិរក្សយ៉ាងហ្មត់ចត់ដោយសមត្ថកិច្ច ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន (http://apsaracentral.com/en/article/12241)។



## សក្តានុពលធនធានធម្មជាតិ

ក្រៅពីប្រាសាទនានាដែលមាននៅក្នុងតំបន់ការពារទេសភាពនេះ នៅមានធនធានធម្មជាតិ ដូចជា ព្រៃឈើ និងសត្វព្រៃផ្សេងៗទៀត។

## សក្តានុពលទេសចរណ៍ធម្មជាតិ

តំបន់ការពារទេសភាពបន្ទាយឆ្មារដែលមានប្រាសាទទន្ទាយឆ្មារ គឺជារមណីយដ្ឋានវប្បធម៌ធម្មជាតិ កំពុងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមានចំនួនពី៧០០-៨០០នាក់ មកទស្សនាកម្សាន្ត ក្នុងមួយឆ្នាំៗ។















## ៤.១២. តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ៣១.១៥៩ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប។ តំបន់ការពារទេសភាពនេះគ្របដណ្តប់ដោយប្រភេទព្រៃលិចទឹក និងវាលស្មៅលិចទឹកបឹងទន្លេសាបតាមរដូវកាល និងជាអចិន្ត្រៃយ៍។ តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។



## សក្តានុពលធនធានធម្មជាតិ

តំបន់ការពារទេសភាពនេះបង្កើតឡើងក្នុងគោលបំណងចម្បង គឺដើម្បីការពារប្រភេទសត្វខ្សឹប ដែលជាប្រភេទជិតផុតពូជទាំងនៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក។ តំបន់នេះជាវាលស្មៅលិចទឹកបឹងទន្លសាបតាមរដូវកាល ដែលផ្តល់ជាជម្រកយ៉ាងសំខាន់សម្រាប់សត្វខ្សឹបរស់នៅ និងពងកូន ដែលគេប៉ាន់ស្មានថា ចំនួនសរុបរបស់វានៅកម្ពុជាមានប្រហែល៦០០ក្បាល ក្នុងនោះមានសត្វខ្សឹបឈ្មោលចំនួន ២៩៤ក្បាល កត់ត្រាបានក្នុងឆ្នាំ២០០៩ (Gray *et al.*, 2009a) ប៉ុន្តែតាមស្ថិតិនៃការសិក្សាស្រាវជ្រាវក្រោយៗមកទៀតបានបង្ហាញថា ចំនួនសរុបរបស់វានៅកម្ពុជានៅសល់តែ៤៣២ក្បាលប៉ុណ្ណោះ (95% CI 312-550) (C. Packman in litt. 2013 , C. Packman et al., 2014) ហើយតំបន់នេះជាជម្រកប្រមូលផ្តុំចំនួនសរុបនៃប្រភេទសត្វខ្សឹបនេះនៅលើពិភពលោកដែលគេប៉ាន់ស្មានថា មានប្រហែលពី ៣៥០ - ១.៥០០ក្បាល (The IUCN Red List of Threatened Species 2018)។ ក្រៅពីប្រភេទសត្វខ្សឹប តំបន់នេះក៏ជាទីជម្រករបស់ប្រភេទសត្វស្លាបទឹកសំខាន់ៗផ្សេងទៀតដូចជា សត្វក្រៀល ត្រដក់ធំ ត្រដក់តូច ពពួកត្រយង រនាលពណ៌។

## សក្តានុពលទេសចរណ៍ធម្មជាតិ

តំបន់ការពារទេសភាពនេះមានសក្តានុពលលើផ្នែកវិស័យទេសចរណ៍ធម្មជាតិ ដែលភ្ញៀវទេសចរមានឱកាសបានឃើញសត្វស្លាបច្រើនប្រភេទ ទិដ្ឋភាពវាលស្មៅ និងព្រៃលិចទឹក ព្រមទាំងការងារកសិកម្មរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងរដូវប្រាំង។ អង្គការ WCS សហការជាមួយមជ្ឈមណ្ឌលសំវាសនាក្នុងខេត្តសៀមរាប បានរៀបចំទេសចរណ៍ទស្សនាសត្វខ្សឹប និងសត្វស្លាបផ្សេងទៀតនៅក្នុងតំបន់នេះ។







តំបន់វាលស្មៅលិចទឹកបឹងទន្លសាបតាមរដូវកាលជាជម្រកយ៉ាងសំខាន់សម្រាប់សត្វខ្សឹប ថតនៅស្រុកស្ទោង ខេត្តកំពង់ធំក្នុងឆ្នាំ២០០២ ដោយ សេង គឹមហ៊ត់





## ៤.១៣. តំបន់ការពារទេសភាពអាងត្រពាំងថ្ម

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាពអាងត្រពាំងថ្ម ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ១២.៦៥០ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ ដើមឡើយ តំបន់នេះគឺជាតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀលអាងត្រពាំងថ្ម បង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យោងតាមទិន្នន័យគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ របស់នាយកដ្ឋានជីវភាពសហគមន៍នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។



## សក្តានុពលធនធានធម្មជាតិ

តំបន់ការពារទេសភាពនេះស្ថិតនៅមិនឆ្ងាយពីតំបន់វាលទំនាបលិចទឹកបឹងទន្លេសាបឡើយ និងជាអាងស្តុកទឹកដ៏ធំមួយដែលមានទឹកជាអចិន្ត្រៃយ៍ ហើយព័ទ្ធជុំវិញដោយតំបន់ដីសើមលិចទឹកតាមរដូវកាល វាលស្រែ និងតំបន់ព្រៃរបោះស្ថិតនៅប៉ែកខាងជើង។ នៅរដូវប្រាំង តំបន់ការពារទេសភាពអាងត្រពាំងថ្មទ្រទ្រង់សត្វក្រៀលរាប់រយក្បាល ដែលមានចំនួនស្មើនឹងពាក់កណ្តាលនៃចំនួនសត្វក្រៀលសរុបដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជានៅតាមតំបន់មួយចំនួនទៀត ដូចជាតំបន់ពារការទេសភាពបឹងព្រែកល្ពៅក្នុងខេត្តតាកែវ តំបន់ពារការទេសភាពអន្លង់ព្រីងក្នុងខេត្តកំពត និងតំបន់វាលស្មៅលិចទឹកបឹងទន្លេសាបតាមរដូវកាល។ ក្នុងរដូវវស្សា សត្វក្រៀលបានបង្កាត់ពូជ និងពងកូននៅក្នុងតំបន់ទេសភាពភាគខាងជើងនៃប្រទេសកម្ពុជារួច ពួកវាបានផ្លាស់ទីមកភាគខាងត្បូងនៃប្រទេស ដើម្បីស្វែងរកចំណី និងស្នាក់អាស្រ័យនៅក្នុងរដូវប្រាំងដែលជារដូវមិនបង្កាត់ពូជ។ តំបន់ការពារទេសភាពអាងត្រពាំងថ្ម ក៏ជាទីជម្រករបស់សត្វស្លាបទឹករាប់ពាន់ក្បាលផ្សេងទៀតផងដែរ មានជាអាទិ៍ពពួករនាល ទុងប្រផេះ និងទាកាបព្រៃ ហើយតំបន់ព្រៃរបោះនៅប៉ែកខាងជើងនៃតំបន់ការពារទេសភាពនេះជាទីជម្រកយ៉ាងសំខាន់សម្រាប់សត្វរមាំងជាច្រើនក្បាល។

## សក្តានុពលទេសចរណ៍ធម្មជាតិ

វត្តមានសត្វព្រៃទាំងនេះ រួមផ្សំជាមួយនឹងតំបន់ផ្ទៃទឹកធំល្វឹងល្វើយ និងស្រស់ស្អាត បានទាក់ទាញភ្ញៀវទេសចររាប់ពាន់នាក់មកទស្សនាកម្សាន្តនៅតំបន់នេះជារៀងរាល់ឆ្នាំ។





ទុងប្រផេះ © Eleanor Briggs/WCS Cambodia


ក្រៀល © Eleanor Briggs/WCS Cambodia


រមាំង @WCS Cambodia

## ៤.១៤.តំបន់ការពារទេសភាព «ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាព «ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ដែលមានផ្ទៃដីសរុប ២.១២៤ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកសង្គមថ្មី ខេត្តព្រះវិហារ។ ការបង្កើតតំបន់នេះឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ធានាការថែរក្សា និងការពារសោភ័ណ្ឌភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ប្រាសាទ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារវប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន។

ប្រាសាទបាកាន ឬ ប្រាសាទព្រះខ័នកំពង់ស្វាយ មានទីតាំងនៅក្នុងភូមិបាកាន ឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ មានចម្ងាយប្រមាណ១០៥គីឡូម៉ែត្រពីក្រុងព្រះវិហារ ឬ អាចចូលទៅដល់តាមផ្លូវក្រួសក្រហមចំពីមុខសាលាស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ បែកចេញពីផ្លូវជាតិលេខ៦ ដែលមានចម្ងាយ៧៥គីឡូម៉ែត្រ ស្ថិតនៅខាងកើតតំបន់អង្គរក្នុងចម្ងាយ១០០គីឡូម៉ែត្រ។ យោងតាមឯកសាររបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានឱ្យដឹងថា ប្រាសាទព្រះខ័នកំពង់ស្វាយ កសាងឡើងនៅសម័យអង្គរនៅពាក់កណ្តាលសតវត្សរ៍ទី១១ និងដើមសតវត្សរ៍ទី១២ ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០)។ ប្រាសាទនេះមានកំពែងពីរជាន់ បើយោងតាមប្រវត្តិវិទូឱ្យដឹងថា ប្រាសាទបាកានក៏ជាទីកន្លែងលាក់ខ្លួនរបស់ព្រះបាទជ័យវរ្ម័នទី៧ មុនពេលព្រះអង្គឡើងគ្រងរាជ្យនៅឆ្នាំ១១៨១ នេះបើតាមរចនាប័ទ្មនៃសំណង់ស្ថាបត្យកម្មខ្លះស្រដៀងគ្នាទៅនឹងរចនាប័ទ្មប្រាសាទបាយ័ន និងប្រាសាទតាព្រហ្មនោះ។ តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។





## សក្តានុពលធនធានធម្មជាតិ

ពីមុនតំបន់នេះមានព្រៃឈើច្រើន ដែលហ៊ុមព័ទ្ធដោយបារាយណ៍ មានស្ទឹង ដងអូរ និងមានប្រភពទឹកធ្លាក់ចុះពីភ្នំដងរែក។ ជាងនេះទៀត ប្រាសាទនេះស្ថិតនៅជាប់តំបន់រ៉ែដែក ដែលអាចស្លធ្វើជាឧបករណ៍សឹកសម្រាប់កងទ័ព កាលសម័យអតីតកាល (https://km.wikipedia.org/wiki/ប្រាសាទព្រះខ័ន_(កំពង់ស្វាយ)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

លោកតា ពិន ប៉ាត (មានវ័យ៦០ឆ្នាំ) ជាឆ្មាំប្រាសាទបាកាន តាំងពីឆ្នាំ២០០៨ បានឱ្យដឹងថា អ្នកស្រុកតែងធៀងចូលទៅអុជធូបដើម្បីបន់ស្រន់សុំសេចក្តីសុខ មុនពេលចូលទៅប្រាសាទបាកាន និងភ្ញៀវទេសចរខ្មែរយើងនៅឆ្ងាយៗមិនសូវស្គាល់ ទើបមិនសូវមកលេង ហើយមានតែអ្នកភូមិក្បែរៗប៉ុណ្ណោះមកលេងនៅរដូវបុណ្យទានធំៗ ដូចចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ តែជារៀងរាល់ថ្ងៃ មានតែភ្ញៀវបរទេសមកមើលតិចតួចជាហូរហែមិនសូវខាននោះទេ (សារព័ត៌មានភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ https://www.postkhmer.com/ទេសចរណ៍/ប្រាសាទបាកាន)។



## ៤.១៥.តំបន់ការពារទេសភាព «នោមដូនសំ»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាព «នោមដូនសំ» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលមានផ្ទៃដីសរុប ១.៤២៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ តំបន់ការពារទេសភាពនេះមានសហគមន៍តំបន់ការពារធម្មជាតិចំនួន ៥កន្លែង ដែលគ្របដណ្ដប់លើផ្ទៃដីសរុប ៥០០ហិកតា និងមានចំនួន១.០០៩គ្រួសារ។




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 242581 | 1497324 | 21 | 240235 | 1493582 |
| 2 | 242581 | 1496324 | 22 | 240023 | 1493664 |
| 3 | 241844 | 1496324 | 23 | 239524 | 1493673 |
| 4 | 241604 | 1496165 | 24 | 238989 | 1493693 |
| 5 | 241855 | 1495965 | 25 | 238402 | 1493715 |
| 6 | 242072 | 1495969 | 26 | 238691 | 1494087 |
| 7 | 242089 | 1495830 | 27 | 238724 | 1494595 |
| 8 | 241498 | 1495782 | 28 | 238760 | 1494890 |
| 9 | 241414 | 1495462 | 29 | 238394 | 1495134 |
| 10 | 240676 | 1495099 | 30 | 238315 | 1494746 |
| 11 | 240756 | 1494824 | 31 | 238164 | 1494804 |
| 12 | 241286 | 1495088 | 32 | 237863 | 1494725 |
| 13 | 242059 | 1494981 | 33 | 237521 | 1495376 |
| 14 | 242048 | 1494651 | 34 | 237985 | 1495610 |
| 15 | 241961 | 1493943 | 35 | 238449 | 1495661 |
| 16 | 241675 | 1493738 | 36 | 238490 | 1495883 |
| 17 | 241270 | 1493563 | 37 | 238077 | 1495957 |
| 18 | 240889 | 1493269 | 38 | 238732 | 1496313 |
| 19 | 240870 | 1493008 | 39 | 237581 | 1496324 |
| 20 | 240333 | 1493419 | 40 | 237581 | 1497324 |

## សក្តានុពលធនធានធម្មជាតិ

តំបន់ការពារទេសភាពនេះមិនសូវមានវត្តមានសត្វព្រៃទេ ដោយសារទីជម្រករបស់ពួកវាត្រូវបានបាត់បង់ និងតំបន់ព្រៃឈើមានលក្ខណៈរេចរឹល នៅមានសេសសល់តែដំណុះកូនឈើតូចៗ និងព្រៃឫស្សីតែប៉ុណ្ណោះ (យោងតាមរបាយការណ៍របស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យឆ្នាំ២០១៩)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

មិនទាន់រកឃើញរបាយការណ៍ ឬ មានឯកសារណាមួយពិពណ៌នាអំពីការសិក្សាស្រាវជ្រាវលើធនធានសត្វព្រៃ និងជីវៈចម្រុះនៅក្នុងតំបន់នេះនៅឡើយ។ បើតាមរបាយការណ៍ តំបន់នេះគ្មានសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិទេ។



សកម្មភាពល្បាតរបស់មន្ត្រីឧទ្យានុរក្ស © មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ



© មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ

## ៤.១៦. តំបន់ការពារទេសភាព «សំបូរព្រៃគុក»

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់ការពារទេសភាព «សំបូរព្រៃគុក» ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ដែលមានផ្ទៃដីសរុប ៤៣៨ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ ការបង្កើតតំបន់នេះឡើងក្នុងគោលបំណងដូចខាងក្រោម៖

- ធានាការថែរក្សា និងការពារសោភ័ណ្ឌភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ និងវប្បធម៌
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិក្នុងតំបន់ប្រាសាទ
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់
- ថែរក្សាការពារវប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន។

ប្រាសាទសំបូរព្រៃគុក មានចម្ងាយ៣៧គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ តាមផ្លូវជាតិ៦៤ បត់ស្តាំតាមសាលាវិស័យ កាត់តាមផ្លូវបុសស្រមោចដែលលិចទឹកនៅរដូវវស្សា តែគេអាចធ្វើដំណើរឆ្ពោះទៅស្រុកសំបូរបានតែម្តង។ ក្រុមប្រាសាទនេះសាងសង់អំពីឥដ្ឋតាន់ និងថ្មបាយក្រៀម លម្អទៅដោយចម្លាក់ពីលើឥដ្ឋចាក់ពុម្ពដោយបាយអជាផ្ទាំងៗអំពីឥដ្ឋ តែបច្ចុប្បន្នរបេះអស់ហើយ។ ប្រាសាទនេះកសាងឡើងនៅរជ្ជកាលស្តេចឥសានវរ្ម័នទី១ នៅក្នុងសតវត្សរ៍ទី៧ (គ.ស.៦១៦-៦៣៥) នាសម័យចេនឡា។ ក្រុមប្រាសាទសំបូរព្រៃគុកនេះត្រូវបានបោះបង់ចោលតាំងពីឆ្នាំ១៩៧១មកម្លេះ និងត្រូវបានរៀបចំសារជាថ្មីនៅឆ្នាំ១៩៨០ ហើយគេបានរកឃើញមានប្រាសាទទាំងអស់ចំនួន១៤០ប្រាសាទ ដែលចែកចេញជា៤ក្រុមធំៗគឺ៖

១. ក្រុមប្រាសាទខាងជើង៖ ហៅថា ប្រាសាទសំបូរនៅកណ្តាល និងព័ទ្ធជុំវិញដោយប្រាសាទតូចៗហើយប្លែកៗគ្នា

២. ប្រាសាទកណ្តាល៖ ហៅថា ប្រាសាទតោ ប្រាង្គប្រាសាទកណ្តាលមានទ្វារចូលពីទិសខាងជើង ឯទ្វារបើកពីទិសមួយទៀតជាទ្វារបញ្ឆោត។ នៅត្រង់ក្បាលជណ្តើរទាំង៤ មានរូបតោអង្គុយបញ្ឈរជង្គង់ពីរក្នុងទិសនីមួយៗ ហៅថា ទេវកថា។ នៅភាគខាងលិចនៃប្រាសាទតោ មានក្រុមប្រាសាទតូចៗជាច្រើនទៀត

៣. ក្រុមប្រាសាទខាងត្បូង៖ ហៅថា ប្រាសាទយាយព័ន្ធ ដែលស្ថិតនៅចំកណ្តាលហ៊ុមព័ទ្ធដោយប្រាសាទជាច្រើន មានកំពែងពីរជាន់ ដែលកំពែងខាងក្នុងមានតោបុរៈ ចូលទាំងបួនទិស។ ក្រុមប្រាសាទទាំងនេះ ជាអតីតរាជធានី

៤. ក្រុមប្រាសាទក្រោលមាស៖ មានទីតាំងនៅខាងជើងប្រាសាទសំបូរព្រៃគុក មានប្រាសាទតូចៗធ្វើអំពីឥដ្ឋ និងខាងលិចមានប្រាសាទមួយធ្វើអំពីថ្មបាយក្រៀម។

ប្រាសាទសំបូរព្រៃគុកត្រូវបានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក ក្នុងកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅទីក្រុង Krakow នៃប្រទេសប៉ូឡូញ កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ (https://km.wikipedia.org/wiki/)។ តំបន់ការពារទេសភាពនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ។




## សក្តានុពលធនធានធម្មជាតិ

យោងតាមឯកសារខ្លះបានពិពណ៌នាថា ប្រាសាទសំបូរព្រៃគុកមានដើមឈើតូចធំ រុក្ខជាតិ និងសត្វផ្សេងៗ គួរឱ្យចាប់អារម្មណ៍។ បច្ចុប្បន្នមិនទាន់រកឃើញរបាយការណ៍ ឬ ឯកសារណាមួយនៃការសិក្សាស្រាវជ្រាវធនធានសត្វព្រៃ និងជីវៈចម្រុះនៅក្នុងតំបន់នេះនៅឡើយទេ។

## សក្តានុពលទេសចរណ៍ធម្មជាតិ

រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក គឺជាប្រភេទរមណីដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រ រួមផ្សំជាមួយនឹងដើមឈើតូចធំ និងប្រភេទសត្វព្រៃមួយចំនួន បានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាកម្សាន្តជាច្រើន ដែលជួយបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ និងជួយផ្សព្វផ្សាយនូវវប្បធម៌របស់ខ្មែរឱ្យកាន់តែច្រើនទៀតផង។






## ៤.១៧. តំបន់រ៉ាមសារបឹងទន្លេឆ្មារ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់រ៉ាមសារបឹងទន្លេឆ្មារ ដែលមានផ្ទៃដីសរុប ២៨.០០០ហិកតា ត្រូវបានផ្តល់សច្ចាប័នដាក់បញ្ចូលក្នុងបញ្ជីនៃអនុសញ្ញារ៉ាមសារដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេស ជាទីជម្រកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាមសារ ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧១។ តំបន់រ៉ាមសារបឹងទន្លេឆ្មារ ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ និងខេត្តសៀមរាប (https://rsis.ramsar.org/ris/997) រួមបញ្ចូលទាំងប្រព័ន្ធព្រែក ដែលជាប់ជាមួយទំនាបព្រៃលិចទឹកបឹងទន្លេសាប នៅប៉ែកឦសាននៃបឹង ហើយជាផ្នែកមួយនៃអាងស្តុកទឹកទន្លេមេគង្គ និងជាតំបន់ស្ថិតនៅជិតចំណុចកណ្តាលនៃបឹងទន្លេសាបលើមាត់បឹងប៉ែកខាងជើងក្នុងឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ ឃុំនេះមានភូមិអណ្តែតមួយចំនួន ដូចជាភូមិព្រៃវើយ ភូមិពាមបាង ភូមិដូនស្តើង ។ល។ ដែលភូមិទាំងនេះមានទីតាំងស្ថិតនៅក្បែរតំបន់រ៉ាមសារបឹងទន្លេឆ្មារ។




### សក្តានុពលធនធានធម្មជាតិ

តំបន់រ៉ាមសារនេះ ស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប ដែលជាជម្រកសត្វព្រៃយ៉ាងសំខាន់ មានបឹងមួយដែលព័ទ្ធជុំវិញដោយព្រៃលិចទឹកនៅប៉ែកពាយ័ព្យនៃបឹងទន្លេសាប មានតំបន់ទឹកលម្ហអចិន្ត្រៃយ៍ មានប្រព័ន្ធផ្លូវទឹកតូចៗ និងតំបន់ព្រៃលិចទឹក។ នៅរដូវវស្សា ផ្ទៃទឹកក្នុងបឹងទន្លេឆ្មាររីកធំ ជាប់ជាមួយនឹងបឹងទន្លេសាប។ តំបន់នេះមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យជលសាស្ត្រ និងជីវវិទ្យានៃប្រព័ន្ធ

ទន្លេសំខាន់ៗពីរ គឺស្ទឹងស្មោង និងស្ទឹងជីក្រែង។ តំបន់នេះសម្បូរទៅដោយរុក្ខជាតិ មច្ឆជាតិ (ដូចជាត្រីរាជ ត្រីគល់រាំង) ថនិកសត្វ (ភេខ្លួនរលោង ខ្លាត្រី) និងពពួកសត្វស្លាបទឹក ដែលភាគច្រើនជាប្រភេទជិតផុតពូជ និងរងគ្រោះថ្នាក់នៅលើពិភពលោក ដូចជា រនាលស រនាលពណ៌ ត្រដក់តូច ត្រដក់ធំ ទុងប្រផេះ ពពូលទឹក និងស្មោញ (Information Shheet on Ramsar Wetlands, 1999)។

### សក្តានុពលទេសចរណ៍ធម្មជាតិ

ធនធានធម្មជាតិ ដូចជាព្រៃលិចទឹក សត្វស្លាបទឹក និងទិដ្ឋភាពភូមិបណ្តែតទឹក ផ្តល់នូវសក្តានុពលសម្រាប់វិស័យទេសចរណ៍ធម្មជាតិ។



ចង្កៀលខ្យង កំពុងស្វែងរកចំណីក្នុងបឹងទន្លេឆ្មារ © Bou Vorsak (០៩-០៥-២០១២)



ត្រដក់ធំ © Sun Visal/WCS Cambodia

## ៤.១៨. តំបន់រ៉ាមសារស្ទឹងសែន

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់រ៉ាមសារស្ទឹងសែន ដោយរួមបញ្ចូលទាំងតំបន់ស្នូលស្ទឹងសែននៃតំបន់បឋបនីយជីវមណ្ឌលបឹងទន្លេសាប និងតំបន់ដីសើមជុំវិញ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានផ្ទៃដីសរុប ៩.២៩៣ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ តំបន់រ៉ាមសារស្ទឹងសែន ជាតំបន់មួយក្នុងចំណោមតំបន់រ៉ាមសារពីរទៀត គឺតំបន់រ៉ាមសារបឹងទន្លេឆ្មារ និងតំបន់រ៉ាមសារព្រែកទាល់ ដែលជាជម្រកសត្វព្រៃយ៉ាងសំខាន់នៅក្នុងតំបន់បឋបនីយជីវមណ្ឌលបឹងទន្លេសាប ជាពិសេសជាបន្ទាយពងកូនរបស់សត្វស្លាបទឹកក្នុងរដូវប្រាំង។



## សក្តានុពលធនធានធម្មជាតិ

ព្រៃឈើដែលដុះច្រើនលប់ក្នុងតំបន់រាមសារស្ទឹងសែននេះ គឺជាប្រភេទព្រៃរបោះលំហ និងជាតំបន់ដីសើម ដែលមានព្រៃលិចទឹក និងវាលស្មៅលិចទឹកជាអចិន្ត្រៃយ៍ និងតាមរដូវកាល។ ព្រៃលិចទឹកក្នុងតំបន់នេះត្រូវបានលិចទឹកជំនន់នៅរដូវវស្សា ហើយនៅរដូវប្រាំង ក្រោយពេលទឹកស្រកវិញ បន្សល់ទុកទឹកនៅតែក្នុងដងស្ទឹងសែន នៅតាមដៃស្ទឹងធំៗ និងនៅតាមត្រពាំងតូចៗតែប៉ុណ្ណោះ។ តំបន់នេះបានផ្តល់នូវទីជម្រកសម្រាប់ពពួកសត្វស្លាបប្រមាណ៧៩ប្រភេទ ដូចជាត្រដក់ធំ ត្រដក់តូច ស្មោញ ទុងប្រផេះ អង្កត់ខ្មៅ អកត្រីក្បាលប្រផេះ, ថនិកសត្វប្រមាណ៩ប្រភេទ មានដូចជាស្វាព្រាម ភេខ្លួនរលោង និងត្រីប្រមាណ៩៤ប្រភេទរួមមានប្រភេទត្រីរាជផងដែរ (BirdLife International Cambodia Programme, 2016: RICH IN BIODIVERSITY)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

ធនធានធម្មជាតិ ដូចជាព្រៃលិចទឹក សត្វស្លាបទឹក និងទិដ្ឋភាពភូមិបណ្តែតទឹក ផ្តល់នូវសក្តានុពលសម្រាប់វិស័យទេសចរណ៍ធម្មជាតិ។



## ៤.១៩. តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ដែលមានផ្ទៃដីសរុប ២៥.២៦៩,៤១ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកត្បែងមានជ័យ ស្រុកសង្គមថ្មី ស្រុកគូលែន ស្រុករវៀង និងក្រុងព្រះវិហារ នៃខេត្តព្រះវិហារ។ តំបន់បេតិកភណ្ឌធម្មជាតិនេះគ្មានសហគមន៍តំបន់ការពារធម្មជាតិទេ កន្លងមកសហគមន៍បានរៀបចំឯកសារដាក់ស្នើសុំមកក្រសួងបរិស្ថានរួចហើយ ដើម្បីបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួន៣កន្លែងគឺ សហគមន៍តំបន់ការពារធម្មជាតិតាំងយូរដែលមានផ្ទៃដីសរុប១.៤៤៧ហិកតា សហគមន៍តំបន់ការពារធម្មជាតិជាតារឹកដែលមានផ្ទៃដីសរុប១.៦៩៣ហិកតា និងសហគមន៍តំបន់ការពារធម្មជាតិចាក់អង្រែដែលមានផ្ទៃដីសរុប ១.១៦៦ហិកតា។

### សក្តានុពលធនធានធម្មជាតិ

យោងតាមឯកសារស្រាវជ្រាវបឋម តំបន់បេតិកភណ្ឌធម្មជាតិនេះនៅមានសេសសល់ព្រៃឈើដ៏សម្បូរបែប ដែលជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ហើយមានសារៈសំខាន់ខ្ពស់សម្រាប់ការអភិរក្សសត្វព្រៃ ការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ី និងជានាទូវការផ្គត់ផ្គង់ទឹកសាបដល់សហគមន៍រស់នៅជុំវិញតំបន់នេះ។ ពពួកថនិកសត្វជិតផុតពូជ និងរងគ្រោះថ្នាក់ជាច្រើនប្រភេទ ត្រូវបានគេដឹងថា មានវត្តមាននៅក្នុងតំបន់នេះ រួមមាន ទោចម្កុដ ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច កែះ ប្រើស ឆ្កែព្រៃ ឆ្មាដាវ ស្វាព្រាម ញើប្រផេះ ប្រចៀវភ្នំត្បែង (Wroughton's Free-tailed Bat *Otomops wroughtoni*) និងមានសត្វព្រៃជាច្រើនប្រភេទផ្សេងទៀត (WCS: Latest News, 2017)។ ប្រភេទឈើសំខាន់ៗនៅមានវត្តមាននៅឡើយក្នុងតំបន់នេះ ដូចជា នាងនួន ដូនថែម ធ្នង់ បេង ក្រញូង តាត្រាវ ផ្ចឹក គគីរ កកោះ ឈើទាល និងមានរុក្ខជាតិច្រើនប្រភេទ ដូចជា កេសរកូល (ផ្កាអរគីដេ) យិនស៊ិនភ្នំត្បែង រុក្ខជាតិឱសថបុរាណ ដូចជា វល្លិគុយ មុខឈ្លាង ផ្ទៃស្រែង (ថ្នាំព្យាបាលក្រពះ) ដើមគោមួយដើងចាប អន្ទង់ស (រាយការណ៍ដោយលោកពូ ចាន់ វណ្ណ ប្រធានសហគមន៍ និងលោក ពុធ ជ័យ គ្រូថ្នាំបុរាណ រស់នៅជើងភ្នំត្បែង)។ ជាងនេះទៀត មានរូងប្រចៀវ និងទឹកធ្លាក់ជាច្រើនកន្លែង។

### សក្តានុពលទេសចរណ៍ធម្មជាតិ

តំបន់បេតិកភណ្ឌនេះ មានទិដ្ឋភាពព្រៃឈើស្រស់ស្អាត រួមជាមួយនឹងតំបន់ទឹកធ្លាក់ជាច្រើនកន្លែង ដូចជាទឹកធ្លាក់តាំងយូ ទឹកធ្លាក់ចាក់អង្រែ ទឹកធ្លាក់អន្លង់ស្វាយ ពើងព្រះរយ គួបផ្សំជាមួយសត្វព្រៃ វត្តតាំងយូ និងមានទីតាំងជំនឿជាច្រើនកន្លែង ដែលដើមឡើយអ្នកភូមិនិយាយថាស័ក្តិសិទ្ធខ្លាំងណាស់ ហើយគេនៅតែមានជំនឿ រួមទាំងជនជាតិគួយផងដែរ។ ទាំងនេះធ្វើឱ្យតំបន់នេះមានសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិ។



ប្រចៀវភ្នំត្បែង © WCS-Cambodia



ព្រៀបប្រអប់ © WCS-Cambodia




និយាមការគោល

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 492836 | 1503372 | | | |
| 2 | 492605 | 1505329 | | | |
| 3 | 492772 | 1507314 | | | |
| 4 | 491538 | 1508765 | 29 | 475323 | 1524655 |
| 5 | 490360 | 1509588 | 30 | 477117 | 1523808 |
| 6 | 488448 | 1509003 | 31 | 479049 | 1523323 |
| 7 | 486852 | 1509851 | 32 | 480813 | 1522552 |
| 8 | 485289 | 1510932 | 33 | 482791 | 1522804 |
| 9 | 484963 | 1512665 | 34 | 484784 | 1522967 |
| 10 | 483725 | 1513458 | 35 | 486768 | 1523207 |
| 11 | 481780 | 1513885 | 36 | 488761 | 1523279 |
| 12 | 479788 | 1513980 | 37 | 490658 | 1522731 |
| 13 | 478280 | 1515156 | 38 | 492052 | 1521334 |
| 14 | 478393 | 1516852 | 39 | 493036 | 1519595 |
| 15 | 479562 | 1517082 | 40 | 493669 | 1517697 |
| 16 | 480152 | 1517063 | 41 | 493755 | 1515753 |
| 17 | 480426 | 1518896 | 42 | 495097 | 1514520 |
| 18 | 481713 | 1519605 | 43 | 495839 | 1512663 |
| 19 | 482918 | 1520889 | 44 | 496901 | 1510980 |
| 20 | 482859 | 1521016 | 45 | 497484 | 1509154 |
| 21 | 480871 | 1521217 | 46 | 499328 | 1509217 |
| 22 | 478885 | 1521433 | 47 | 500305 | 1507534 |
| 23 | 476930 | 1521414 | 48 | 499681 | 1505699 |
| 24 | 474950 | 1521359 | 49 | 500778 | 1504028 |
| 25 | 473432 | 1522629 | 50 | 501028 | 1502180 |
| 26 | 472064 | 1524055 | 51 | 499193 | 1501906 |
| 27 | 471923 | 1525941 | 52 | 497243 | 1502134 |
| 28 | 473752 | 1525880 | 53 | 495342 | 1501635 |




ទេសភាពលើខ្នងភ្នំត្បែង @ Ea Sokha ( May 2018)


ប្រភេទផ្កាជុះនៅលើខ្នងភ្នំត្បែង ផ្តល់ឱ្យដោយលោក នូ សុខ


SHOT ON OPPO
ទឹកធ្លាក់ចាក់អង្រែ នៅលើខ្នងភ្នំត្បែង ផ្តល់ឱ្យដោយលោក នូ សុខ




ថ្មដល់ នៅលើខ្នងភ្នំត្បែង © នូ សុខ



## ៤.២០. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំជញ្ជាំង

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ១៩ហិកតា ស្ថិតក្នុងភូមិសាស្ត្រសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ តំបន់បេតិកភណ្ឌធម្មជាតិនេះ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ មានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីក្រុងសិរីសោភ័ណ បត់ចូលតាមក្លោងទ្វារវត្តកុឧបុព្វតាភ្នំជញ្ជាំង។ អនុក្រឹត្យនេះមានគោលបំណងដូចតទៅៈ

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | [illegible] | 1503333 | 16 | 277030 | 1502970 |
| 2 | 277632 | 1503366 | 17 | 277058 | 1502935 |
| 3 | 277639 | 1503393 | 18 | 277104 | 1502953 |
| 4 | 277615 | 1503404 | 19 | 277171 | 1502974 |
| 5 | 277552 | 1503421 | 20 | 277159 | 1502996 |
| 6 | 277430 | 1503421 | 21 | 277201 | 1503031 |
| 7 | 277336 | 1503381 | 22 | 277224 | 1503007 |
| 8 | 277194 | 1503313 | 23 | 277262 | 1503040 |
| 9 | 277144 | 1503235 | 24 | 277261 | 1503025 |
| 10 | 277041 | 1503245 | 25 | 277341 | 1503048 |
| 11 | 276932 | 1503200 | 26 | 277334 | 1503069 |
| 12 | 276810 | 1503162 | 27 | 277430 | 1503093 |
| 13 | 276809 | 1503042 | 28 | 277397 | 1503209 |
| 14 | 276925 | 1502979 | 29 | 277432 | 1503254 |
| 15 | 276989 | 1502976 | 30 | 277578 | 1503333 |

## សក្តានុពលធនធានធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិនេះ នៅមានព្រៃឈើធម្មជាតិដុះច្រើនលាយឡំជាមួយនឹងផ្ទាំងថ្មបញ្ឈរធំៗជាច្រើន មានវត្តមានសត្វព្រៃ និងមានរូងប្រចៀវ (ឯកសារស្តីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

ភ្នំជញ្ជាំងគឺជារមណីយដ្ឋានធម្មជាតិ និងវប្បធម៌ ដែលមានផ្ទាំងថ្មបញ្ឈរធំៗជាច្រើន ដូចជញ្ជាំងផ្ទះ មានព្រៃឈើ និងសត្វព្រៃ ហើយជាទីកន្លែងដែលប្រជាពលរដ្ឋមានជំនឿខ្លាំង។ ក្រៅពីនេះ មានសំណង់ថ្មីៗដែលមានលក្ខណៈជាបុរាណសម្រាប់ឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាកម្សាន្តលំហែអារម្មណ៍។ អ្វីដែលពិសេសទៀតនោះគឺ នៅបាតភ្នំជញ្ជាំង មានល្អាងមួយនៅក្នុងដី ដែលមានជម្រៅ១២ម៉ែត្រ និងផ្ទៃល្អាងមានទំហំ១០ម៉ែត្រការ៉េ ជាទីកន្លែងដែលគេអាចចុះទៅកម្សាន្តបាន។ ភ្ញៀវទេសចរអាចគយគន់ទិដ្ឋភាពដ៏ស្រស់ស្អាតនៃក្រុងសិរីសោភ័ណ និងវាលស្រែធំល្វឹងល្វើយ ពីលើខ្នងភ្នំជញ្ជាំងនេះ (https://news.sabay.com.kh/article/885430)។


















## ៤.២១. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះនេត្រព្រះ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះនេត្រព្រះ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ១៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទេស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




### សក្តានុពលធនធានធម្មជាតិ

មានព្រៃឈើធម្មជាតិដុះនៅតាមជើងភ្នំ និងនៅលើខ្នងភ្នំ និងមានវត្តមានសត្វព្រៃ (ឯកសារស្តីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។

## សក្ដានុពលទេសចរណ៍ធម្មជាតិ

បន្ទាប់ពីតំបន់បេតិកភណ្ឌធម្មជាតិនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល អង្គភាពកងទ័ពរថក្រោះ និងអាជ្ញាធរមានសមត្ថកិច្ច បានរួមគ្នារៀបចំកែលម្អទីតាំង និងបរិវេណរថក្រោះថ្ម និងភ្នំព្រះនេត្រព្រះឱ្យទៅជារមណីយដ្ឋានទេសចរណ៍ថ្មីមួយ ដើម្បីទាក់ទាញភ្ញៀវទេសចរមកកម្សាន្ត ហើយក៏ជាទីកន្លែងដែលប្រជាពលរដ្ឋមានជំនឿខ្លាំង មានថ្លុកទឹក និងស្នាមព្រះបាទ។ កន្លងមក ភ្ញៀវទេសចរដែលមកទស្សនាកម្សាន្តនៅទីនោះតែងតែបានថតរូបជាមួយនឹងរថក្រោះធ្វើអំពីថ្ម (https://kohsantepheapdaily.com.kh/article/1108425.html)។















## ៤.២២. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះ-ភ្នំវែង

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះ-ភ្នំវែង ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ១.៥០០ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ អនុក្រឹត្យមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




### សក្តានុពលធនធានធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិនេះ មានវត្តមានសត្វព្រៃជាច្រើនប្រភេទ ដូចជា ឈ្លូស ជ្រូកព្រៃ ឆ្កែចចក សំពោច កាំប្រមា អន្សង ត្រកួត ជាស ពស់ មាន់ព្រៃ ក្រួច ក្ងោក ទន្សាយ កេងកង តាវៅ សេក ប្រវឹក ជាដើម។ នៅក្នុងព្រៃនេះ មានដើមឈើទាល ធ្នង់ បេង សុក្រំ ផ្ចឹក រាំង កកោះ អង្គាញ់ អង្គោល ពង្រ ព្រីង និងមាន

ប្រភេទឈើផ្កា ដូចជា កញ្ញាច ប្រាំដំឡឹង ត្របែកព្រៃ បុស្ស កំភ្លឹង និងអនុផលព្រៃឈើផ្សេងទៀត មានដូចជាផ្សិត (www.rasmeinews.com)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិនេះ មានកសក្តានុពលទេសចរណ៍ធម្មជាតិ ដោយសារនៅមានព្រៃឈើ និងមានវត្តមានសត្វព្រៃ មានល្អាង មានអាស្រម និងរូបសំណាកបុរាណ រួមជាមួយទីតាំងប្រវត្តិសាស្ត្រ ភ្នំព្រះ-ភ្នំវែងនេះ ដែលជាទីកន្លែងគោរពសក្ការៈ និងប្រជាពលរដ្ឋមានជំនឿខ្លាំង។


















## ៤.២៣. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំយាយសំ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិភ្នំយាយសំ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ៤១៦ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ អនុក្រឹត្យមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទេស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




### សក្តានុពលធនធានធម្មជាតិ

នៅមានសេសសល់ព្រៃឈើដុះច្រើន មានវត្តមានសត្វព្រៃ និងមានរូងប្រចៀវ (ឯកសារស្តីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។

## សក្តានុពលទេសចរណ៍ធម្មជាតិ

បច្ចុប្បន្ន តំបន់បេតិកភណ្ឌធម្មជាតិនេះ គឺជាតំបន់ទេសចរណ៍ធម្មជាតិស្រាប់នៅក្នុងខេត្តបន្ទាយមានជ័យ និងមានភ្ញៀវទេសចរមកទស្សនាកម្សាន្តជាហូរហែ។






## ៤.២៤. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិភ្នំបាក់ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ៣៦ហិកតា ស្ថិតក្នុងភូមិសាស្ត្រសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ តំបន់បេតិកភណ្ឌធម្មជាតិនេះ មានចម្ងាយប្រមាណ៥គីឡូម៉ែត្រ ពីក្រុងសិរីសោភ័ណ។ អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទេស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




### សក្តានុពលធនធានធម្មជាតិ

នៅមានសេសសល់ព្រៃឈើដុះច្រើន ជាពិសេសមានប្រភេទឈើក្រញូង មានវត្តមានសត្វព្រៃ និងមានរូងប្រចៀវ (ឯកសារស្តីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្ត

បន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។ តាមការសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានតំបន់បេតិកភណ្ឌនៃក្រសួងបរិស្ថាន បានរកឃើញមានវត្ថុមានរូបរាងផូស៊ីលផ្សេងៗនៅក្នុងតំបន់នេះ។

## សក្តានុពលទេសចរណ៍ធម្មជាតិ

តំបន់បេតិកភណ្ឌនេះ មានទេសភាពស្អាតនៅពេលដែលយើងឡើងទៅមើលពីលើកំពូលភ្នំ ហើយគេអាចគយគន់ព្រះអាទិត្យអស្តង្គត និងមើលឃើញក្រុងសិរីសោភ័ណបានផងដែរ ជាពិសេស មានល្អាងដែលភ្ញៀវទេសចរអាចចូលលេងកម្សាន្តបានប្រកបដោយសុវត្ថិភាព និងសេក្តីសប្បាយរីករាយថែមទៀតផង (https://visitcambodia.travel/kh/item/view/)។











## ៤.២៥. តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំស្វាយ

### ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រ

តំបន់បេតិកភណ្ឌធម្មជាតិភ្នំស្វាយ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានផ្ទៃដីសរុប ១៦ហិកតា ស្ថិតក្នុងភូមិសាស្ត្រសង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ អនុក្រឹត្យមានគោលបំណងដូចតទៅៈ

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទេសនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។




### សក្តានុពលធនធានធម្មជាតិ

នៅមានព្រៃឈើដុះច្រើន និងមានវត្តមានសត្វព្រៃ (ឯកសារស្តីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។ តាមការសិក្សាស្រាវជ្រាវ

របស់នាយកដ្ឋានតំបន់បេតិកភណ្ឌនៃក្រសួងបរិស្ថាន បានរកឃើញមានវត្ថុមានរូបរាងផូស៊ីលផ្សេងៗនៅក្នុងតំបន់នេះ។

### សក្ដានុពលទេសចរណ៍ធម្មជាតិ

តំបន់បេតិកភណ្ឌនេះ ដើមឡើយមានឈ្មោះជា ភ្នំស្វាយស៊ីសុផុន មានព្រះសង្ឃគង់នៅជាច្រើនអង្គ និងមានអាស្រម ដែលជាទីកន្លែងដែលប្រជាពលរដ្ឋមានជំនឿខ្លាំង (ឯកសារស្ដីពីលក្ខណៈសម្បត្តិសុំរៀបចំបង្កើតតំបន់បេតិកភណ្ឌនេះរបស់មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ ក្នុងឆ្នាំ២០១៨)។









## ៥. វាក្យសព្ទ (ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, ឆ្នាំ២០០៨)

**តំបន់ការពារធម្មជាតិ:** តំបន់ការពារធម្មជាតិសំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមានដែនដីគោក ឬ ដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបញ្ញត្តិនៃច្បាប់ ឬ តំបន់ដែលបង្កើតថ្មីក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រ និងផ្នែកជីវសាស្ត្រដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ ក្នុងគោលបំណងការពារ និងថែទាំជីវៈចម្រុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**ឧទ្យានជាតិ:** សំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោក និង/ឬ ដែនទឹកដែលត្រូវបានកំណត់ដើម្បីៈ

ក. ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយ ឬ ច្រើន របស់តំបន់ដែលបានកំណត់សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

ខ. កម្រិតដល់ការប្រើប្រាស់ដែលអាចធ្វើឱ្យ ឬ បំផ្លិចបំផ្លាញដល់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះ ជាមួយនឹងគោលបំណងនៃការកំណត់តំបន់។

គ. ផ្តល់ជាមូលដ្ឋានសម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន។

**ដែនជម្រកសត្វព្រៃ:** សំដៅដល់តំបន់ក្នុងដែនដីគោក ឬ ដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រក និង/ឬ ដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ ឬ រុក្ខជាតិ។

**តំបន់ការពារទេសភាព:** សំដៅដល់តំបន់នៃដែនដីគោក និង/ឬ ដែនទឹក ដែលតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្សទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ដែលមានលក្ខណៈប្លែក ខាងផ្នែកសោភ័ណភាពធម្មជាតិ ឬ កេរ្តិ៍ដំណែលអេកូឡូស៊ី ឬ វប្បធម៌ និងជាទូទៅសម្បូរដោយជីវៈចម្រុះ។ ការថែរក្សាអន្តរអំពើជាប្រពៃណីបែបនេះមានសារៈសំខាន់ជាអាយុជីវិតចំពោះកិច្ចការពារ ថែរក្សា និងការវិវឌ្ឍតំបន់បែបនេះ។

**តំបន់ប្រើប្រាស់ច្រើនយ៉ាង:** សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬ ដែនទឹកដែលក្នុងនោះ មានសម្បូរដោយប្រព័ន្ធធម្មជាតិដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងដែលតម្រូវឱ្យមានសកម្មភាពគ្រប់គ្រងដើម្បីធានាការការពារ និងការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់ពេលយូរអង្វែង។ ទន្ទឹមនឹងនោះដែរ អាចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។

**តំបន់រ៉ាមសារ:** សំដៅដល់តំបន់ដីសើមដែលគេចាត់ទុកថា ជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬ ជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

**តំបន់បម្រុងជីវមណ្ឌល:** សំដៅដល់តំបន់តំណាងឱ្យប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់ និងពុំរងនូវការខូចខាតខ្លាំង ហើយព័ទ្ធជុំវិញទៅដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាព ដែលអនុញ្ញាតឱ្យមានសកម្មភាពមនុស្សក្នុងកម្រិតមួយជាកំណត់។

**តំបន់បេតិកភណ្ឌធម្មជាតិ:** សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬ ដែនទឹក ដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិ ឬ ពាក់កណ្តាលកេរ្តិ៍ដំណែលធម្មជាតិ និងមានតម្លៃលេចធ្លោ ឬ ប្លែកពីគេ ដោយសារ

តំបន់នោះមានដោយកម្រ មានគុណភាពជាតំណាងឱ្យប្រព័ន្ធធម្មជាតិនានា ឬ មានគុណភាពខាងផ្នែកសោភ័ណភាព ឬ សារៈសំខាន់ខាងផ្នែកវប្បធម៌។

**ឧទ្យានជាតិសមុទ្រៈ** សំដៅដល់តំបន់ឆ្នេរសមុទ្រ ទទួលឥទ្ធិពលជំនោរសមុទ្រលាយឡំជាមួយនឹងទឹកពីព្រៃភ្នំ រួមទាំងកោះគ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆជាតិគ្រប់ប្រភេទ មានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ហើយតំបន់នេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

**ជីវៈចម្រុះៈ** សំដៅដល់បណ្តាសារពាង្គកាយខុសៗគ្នានៅក្នុងប្រភេទតែមួយ ឬ ប្រភេទផ្សេងគ្នា និងបណ្តាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ។

## ៦. តួនាទី និងភារកិច្ចរបស់ ន.ដ.គ.ជ

យោងតាមប្រកាសលេខ ១៩៩ ប្រ.ក ប.ស្ថ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងបរិស្ថាន នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប (ន.ដ.គ.ជ) មានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ និងកសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន អភិវឌ្ឍធនធានមនុស្ស គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានាដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ចរបស់នាយកដ្ឋាន
- រៀបចំយុទ្ធសាស្ត្រផែនការគ្រប់គ្រង ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- រៀបចំកំណត់ព្រំប្រទល់ បែងចែកតំបន់គ្រប់គ្រង ធ្វើផែនទី និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- សិក្សាស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិ ជាពិសេសប្រភេទសត្វ និងរុក្ខជាតិដែលមានដោយកម្រ ងាយរងគ្រោះ កំពុងរងគ្រោះ និងជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- ការពារ អភិរក្ស និងស្តារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាបឱ្យមាននិរន្តរភាព
- ចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាព ថែរក្សាប្រពៃណី ទំនៀមទំលាប់របស់សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- ចូលរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ
- ចូលរួមចំណែកបង្ការ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- កៀរគរជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់ការអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាបប្រកបដោយនិរន្តរភាព
- សម្របសម្រួលការអនុវត្តគម្រោងនៅក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- រៀបចំផែនការគ្រប់គ្រង និងចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប

- តាមដាន ត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- អប់រំផ្សព្វផ្សាយដល់សាធារណជន ដើម្បីចូលរួមថែរក្សា និងការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើសធនធានធម្មជាតិ និងបរិស្ថានតាមនីតិវិធីក្នុងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- សហការជាមួយអង្គភាពមានសមត្ថកិច្ច ដៃគូអភិវឌ្ឍន៍ និងអង្គការដៃគូ ដើម្បីការពារអភិរក្ស និងសង្គ្រោះសត្វព្រៃ
- សម្របសម្រួល និងអនុវត្តកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារ ពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប
- ពង្រឹង ពិនិត្យតាមដានការអនុវត្តការងារគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គនាយក។

## ៧. ឯកសារយោង


ប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងបរិស្ថាន (២០១៧) ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ឆ្នាំ២០១៧-២០៣១

ក្រសួងបរិស្ថាន (២០១៧) កម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ២០១៨-២០២៧

ក្រសួងបរិស្ថាន (២០១៧) គោលការណ៍ណែនាំស្តីពីការកំណត់បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ

ក្រសួងបរិស្ថាន (២០១៨) ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ២០១៦

ក្រសួងបរិស្ថាន (២០១៩) របាយការណ៍បូកសរុបលទ្ធផលការងារគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិប្រចាំឆ្នាំ២០១៩ និងទិសដៅការងារអនុវត្ត២០២០

Seng Kim Hout, Pech Bunnat, Poole, C. M., Tordoff, A. W., Davidson,P. and Delattre, E. (2003) *Directory of Important Bird Areas in Cambodia: key sites for conservation*. Phnom Penh: Department of Forestry and Wildlife, Department of Nature Conservation and Protection, BirdLifeInternational in Indochina and the Wildlife Conservation Society CambodiaProgramme

The PAD Partnership (2003) *Cambodia National Report on Protected Areas and Development: Review of protected areas and development in the four countries of the Lower Mekong River Region*. Phnom Penh: Ministry of Environment and Ministry of Economics and Finanace

Forestry Administration (2010) Managament Plan 2010-2014: Preah Vihear Protected Forest for Plant and Wildlife Genertic Resources Conservation

Hayes, B., Mould, A., Eang Hourt Khou, Hartmann, T., Kha Hoa, Calame, Th., Boughey K. and Yon T. (2013) A Biodiversity Assessment of Phnom Kulen National Park, with Recommendations for Management

Hayes, B., Eang Hourt Khou, Neang Thy, Furey, N. Chhin Sophea, Holden, J., Hun Seiha, Phen Sarith, La Pengly and Simpson, V. (2015) BIODIVERSITY ASSESSMENT OF PREY LANG in Kratie, Kampong Thom, Stung Treng and Preah Vihear Provinces

WCS (2016) Prey Preah Roka Wildlife Santuary, Cambodia

*The IUCN Red List of Threatened Species*. Version 2019-2. https://www.iucnredlist.org

# ឧបសម្ព័ន្ធ១៖ ប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ភូមិសាស្ត្រខាងជើងបឹងទន្លេសាប

| ល.រ | តំបន់ការពារធម្មជាតិ | ផ្ទៃក្រឡា (ហ.ត) | ស្ថិតក្នុង ភូមិសាស្ត្រខេត្ត | បង្កើតឡើងដោយ |
|---|---|---|---|---|
| **ឧទ្យានជាតិ (១ កន្លែង)** | | **៣៧.៥០០** | | |
| ១ | ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» | ៣៧.៥០០ | សៀមរាប | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| **ដែនជម្រកសត្វព្រៃ (៧ កន្លែង)** | | **១.៤២៩.៤២២** | | |
| ២ | គូលែន-ព្រហ្មទេព | ៤០២.៥០០ | ព្រះវិហារ សៀមរាប និងឧត្តរមានជ័យ | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ៣ | បឹងពែរ | ២៤២.៥០០ | កំពង់ធំ ព្រះវិហារ និង សៀមរាប | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ៤ | «ព្រៃឡង់» | ៤៣១.៦៨៣ | ស្ទឹងត្រែង កំពង់ធំ ក្រចេះ និងព្រះវិហារ | អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ |
| ៥ | ព្រះរការ | ៩០.៣៦១ | ព្រះវិហារ | អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ |
| ៦ | ឆែប | ១៩០.០២៧ | ព្រះវិហារ និង ស្ទឹងត្រែង | អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ |
| ៧ | «ភ្នំត្នោត-ភ្នំពក» | ៤២.០៩៧ | ព្រះវិហារ និង សៀមរាប | អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ |
| ៨ | «សង្ឃរុក្ខាវ័ន» | ៣០.២៥៤ | ឧត្តរមានជ័យ | អនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ |
| **តំបន់ការពារទេសភាព (៨ កន្លែង)** | | **១៩៤.៧៩៤** | | |
| ៩ | អង្គរ | ១០.៨០០ | សៀមរាប | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ១០ | ព្រះវិហារ | ៥.០០០ | ខេត្តព្រះវិហារ | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ១១ | បន្ទាយឆ្មារ | ៨១.២០០ | បន្ទាយមានជ័យ និង ឧត្តរមានជ័យ | ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ |
| ១២ | ទំនាបខាងជើងទន្លេសាប *(សត្វខ្សឹបៈ ទ្រាសាមគ្គី, ខ្ទូលគ្រើល, បារាយ, ចុងដូង, ស្ទោង និងជីក្រែង)* | ៣១.១៥៩ | កំពង់ធំ និងសៀមរាប | អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ |
| ១៣ | អាងត្រពាំងថ្ម | ១២.៦៥០ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ១០០ អនក្រ.បក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ |
| ១៤ | «ប្រាសាទបាកាន (ព្រះខ័ន កំពង់ស្វាយ)» | ២.១២៤ | ព្រះវិហារ | អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ |
| ១៥ | «នោមដូនសំ» | ១.៤២៣ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ |
| ១៦ | «សំបូរព្រៃគុក» | ៤៣៨ | កំពង់ធំ | អនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ |

| | | | | |
|---|---|---|---|---|
| **តំបន់រ៉ាមសារ (២ កន្លែង)** | | **៣៧.២៩៣** | | |
| ១៧ | តំបន់រ៉ាមសារបឹងទន្លេឆ្មារ | ២៨.០០០ | កំពង់ធំ និងសៀមរាប | ព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ |
| ១៨ | តំបន់រ៉ាមសារស្ទឹងសែន | ៩.២៩៣ | កំពង់ធំ | អនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| **តំបន់បេតិកភណ្ឌធម្មជាតិ (៧ កន្លែង)** | | **២៧.២៦៩,៤១** | | |
| ១៩ | ភ្នំត្បែង | ២៥.២៦៩,៤១ | ព្រះវិហារ | អនុក្រឹត្យលេខ ១៨៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ |
| ២០ | ភ្នំជញ្ជាំង | ១៩ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| ២១ | ភ្នំព្រះនេត្រព្រះ | ១៣ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| ២២ | ភ្នំព្រះ-ភ្នំវែង | ១.៥០០ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| ២៣ | ភ្នំយាយសំ | ៤១៦ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| ២៤ | ភ្នំបាក់ | ៣៦ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| ២៥ | ភ្នំស្វាយ | ១៦ | បន្ទាយមានជ័យ | អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| **ផ្ទៃដីសរុបប្រព័ន្ធតំបន់ការពារធម្មជាតិ (២៥ កន្លែង)** | | **១.៦៧៦.២៧៨,៤១** | | |
| **របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ** | | | | |
| ២៦ | របៀងអភិរក្សជីវៈចម្រុះឧត្តរ | **៥០០.៨១០** | | អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ |

## ឧបសម្ព័ន្ធ២៖ ប្រភេទសត្វព្រៃកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដែលមានវត្តមាននៅក្នុងតំបន់ទេសភាពប៉ែកខាងជើងនៃប្រទេសកម្ពុជា

### ក. ថនិកសត្វ

| ល.រ | ឈ្មោះប្រភេទសត្វ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ IUCN RedList | ចំណាត់ថ្នាក់នៅកម្ពុជា |
|---|---|---|---|---|---|
| ១ | ពង្រូល | Sunda Pangolin | *Manis javanica* | CR | កម្រ |
| ២ | កំពីងដូង | Owston's civet | *Hemigalus owstoni* | EN | បង្គួរ |
| ៣ | ខ្លាដំបង ឬ ខ្លាធំ | Tiger | *Panthera tigris* | EN | ជិតផុតពូជ |
| ៤ | ឆ្កែព្រៃ | Dhole | *Cuon alpinus* | EN | កម្រ |
| ៥ | ដំរី | Asian Elephant | *Elephas maximus* | EN | ជិតផុតពូជ |
| ៦ | ទន្សោង | Banteng | *Bos javanicus* | EN | កម្រ |
| ៧ | ទោចថ្ពាល់លឿង | Yellow-cheeked Gibbon | *Hylobates gabriellae* | EN | កម្រ |
| ៨ | ទោចមកុដ | Pileated gibbon | *Hylobates pileatus* | EN | កម្រ |
| ៩ | ភេរវមច្រមុះ | Hairy-nosed Otter | *Lutra sumatrana* | EN | កម្រ |
| ១០ | រមាំង | Eld's Deer | *Rucervus eldii* | EN | ជិតផុតពូជ |
| ១១ | ស្វាក្រវ៉ាត់ ឬ ស្វាកន្ទុយស | Red-shanked Douc Langur | *Pygathrix nemaeus* | EN | កម្រ |
| ១២ | ស្វាព្រាម | Indochinese Lutung | *Trachypithecus germaini* | EN | បង្គួរ |
| ១៣ | ខ្លារខិន | Leopard | *Panthera pardus* | VU | កម្រ |
| ១៤ | ខ្លាត្រី | Fishing Cat | *Prionailurus viverrinus* | VU | បង្គួរ |
| ១៥ | ខ្លាពពក | Clouded Leopard | *Neofelis nebulosi* | VU | ជិតផុតពូជ |
| ១៦ | ខ្លាឃ្មុំធំ | Asiatic Black Bear | *Ursus thibetanus* | VU | ជិតផុតពូជ |
| ១៧ | ខ្លាឃ្មុំតូច | Sun bear | *Helarctos malayanus* | VU | កម្រ |
| ១៨ | ខ្លាត្រី | Fishing Cat | *Prionailurus viverrinus* | VU | បង្គួរ |
| ១៩ | ខ្ទីង | Gaur | *Bos gaurus* | VU | កម្រ |
| ២០ | ជ្រូកពោន | Greater Hog Badger | *Arctonyx collaris* | VU | កម្រ |
| ២១ | ប្រើស | Sambar | *Cervus unicolor* | VU | បង្គួរ |
| ២២ | ញើប្រផេះ | Bengal slow Loris | *Nycticebus bengalensis* | VU | កម្រ |
| ២៣ | ញើភ្លើង | Pygmy Slow Loris | *Nycticebus pygmaeus* | VU | កម្រ |
| ២៤ | ស្វាគ្រោស | Southern Pig-tailed Macaque | *Macaca nemestrina* | VU | បង្គួរ |
| ២៥ | ស្វាអង្កត់ | Stump-tailed Macaque | *Macaca arctoides* | VU | កម្រ |

## ខ. សត្វស្លាប

| ល.រ | ឈ្មោះប្រភេទសត្វ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ IUCN Redlist | ចំណាត់ថ្នាក់នៅកម្ពុជា |
|---|---|---|---|---|---|
| ១ | ត្មាតត្នោត | Slender-billed Vulture | *Gyps tenuirostris* | CR | កម្រ |
| ២ | ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | CR | កម្រ |
| ៣ | ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | CR | កម្រ |
| ៤ | ត្រយងយក្ស | Giant Ibis | *Pseudibis gigantea* | CR | ជិតផុតពូជ |
| ៥ | ត្រយងចង្កំកស | White-shouldered Ibis | *Pseudibis davisoni* | CR | ជិតផុតពូជ |
| ៦ | ក្ងោក | Green Peafowl | *Pavo muticus* | EN | កម្រ |
| ៧ | ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | EN | ជិតផុតពូជ |
| ៨ | ទាព្រៃស្លាបស | White-winged Duck | *Asarcornis scutulata* | EN | ជិតផុតពូជ |
| ៩ | ពពូលទឹក | Masked Finfoot | *Heliopais personata* | EN | ជិតផុតពូជ |
| ១០ | កុកពាក់អំបោះ | Asian Woollyneck | *Ciconia episcopus* | VU | កម្រ |
| ១១ | កេងកងធំ | Great Hornbill | *Buceros bicornis* | VU | កម្រ |
| ១២ | ក្រៀល | Sarus Crane | *Antigone antigone* | VU | កម្រ |
| ១៣ | ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | VU | កម្រ |
| ១៤ | ត្រសេះដំរី | Great Slaty Woodpecker | *Mulleripicus pulverulentus* | VU | បង្គួរ |
| ១៥ | ពពូលក្បាលព្រលែត | Pale-capped Pigeon | *Columba punicea* | VU | កម្រ |
| ១៦ | មិនទាន់មានឈ្មោះខ្មែរ (ប្រភេទថ្មីក្នុងអម្សូរអេក) | Indian Spotted Eagle | *Clanga hastata* | VU | |

## គ. ឧរង្គសត្វ

| ល.រ | ឈ្មោះប្រភេទសត្វ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ IUCN Redlist | ចំណាត់ថ្នាក់នៅកម្ពុជា |
|---|---|---|---|---|---|
| ១ | អណ្តើកព្រិច | Yellow-headed Tortoise | *Indotestudo elongata* | EN | បង្គួរ |
| ២ | អណ្តើកក្របីក្បាលលឿង | Yellow-headed Temple | *Heosemys annandalii* | EN | បង្គួរ |
| ៣ | កន្ធាយអាស៊ី | Asiatic Softshell Turtle | *Amyda cartilaginea* | VU | បង្គួរ |
| ៤ | ពស់វែករនាម | King Cobra | *Ophiophagus hannah* | VU | កម្រ |
| ៥ | ពស់ថ្លាន់តូច | Burmese Python | *Python bivittatus* | VU | បង្គួរ |
| ៦ | អណ្តើកបិទមុខស្នូកខ្មៅ | Southeast Asian Box Turtle | *Cuora amboinensis* | VU | បង្គួរ |
| ៧ | អណ្តើកសកល | Mekong Snail-eating Turtle | *Malayemys subtrijuga* | VU | បង្គួរ |
| ៨ | អណ្តើកសោមញី | Giant Asian Pond Turtle | *Heosemys grandis* | VU | បង្គួរ |
| ៩ | អណ្តើកក្អែកខ្មៅ | Black Marsh Turtle | *Siebenrockiella crassicollis* | VU | បង្គួរ |

**សម្គាល់៖** យោងតាមបញ្ជីក្រហមរបស់អង្គការ IUCN ប្រភេទសត្វព្រៃទទួលរងការគំរាមកំហែងក្នុងពិភពលោក (Globally Threatened Species) រួមមាន៣ចំណាត់ថ្នាក់ ១) ប្រភេទជិតផុតពូជ (Critically Endangered = CR), ២) ប្រភេទរងគ្រោះថ្នាក់ (Endangered = EN) និង ៣) ប្រភេទងាយរងគ្រោះ (Vulnerable = VU)។